# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២១-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៨៦ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះ សពឯកឧត្តម **ជ័យ សាផុន** នូវគ្រឿងឥស្សរិយយស ជាតូបការ ៩០៣៧

២១-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៨៧ ស្តីពី ការតែងតាំង លោក **ឆៃ វណ្ណថន** ជាឧកញ៉ា ៩០៣៨

២១-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៨៨ ស្តីពី ការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ឯក **ឃុន សំបូរ** ជា ទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្សរ៍ ៩០៣៩

២១-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៨៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **អ៊ែល សំនាង** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩០៤០

២១-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **គាំ ឈន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩០៤១

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩១ ស្តីពី ការតែងតាំង អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងនីតិកាលទី ៥ នៃរដ្ឋសភា ចំនួន ០២ រូប ៩០៤២

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩២ ស្តីពី ការតែងតាំង ឯកឧត្តម ហង្ស វិចិត្រ ជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ៩០៤៣

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ថាង ហ្សុំងស៊ី** (TANG SHUANGXI) ជនជាតិចិន សញ្ជាតិចិន កើតនៅខេត្តហ្ស៊ីរណាន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង ពីវ** (TANG BIAO) ៩០៤៤

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អាលិកហ្សង់ឌ័រ វ៉ាង** (ALEXANDER WANG) ជនជាតិឥណ្ឌូនេស៊ី សញ្ជាតិឥណ្ឌូនេស៊ី កើតនៅខេត្តស៊ីងការ៉ាង សាធារណរដ្ឋឥណ្ឌូនេស៊ី ៩០៤៥

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៥ ស្ដីពី ការតម្លើងឋានន្តរស័ក្តិ នាយឧត្តមសេនីយ៍ ជូនឯកឧត្តមឧត្តមសេនីយឯក **ភាន់ សុខន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៩០៤៦

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៦ ស្ដីពី ការប្ដូរប្រភេទក្របខ័ណ្ឌ ជូនមន្ត្រីរាជការ ០២ រូប ជាករណីពិសេស ពីឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងពីឋានន្តរស័ក្តិលេខាធិការដ្ឋានដើមខ្សែ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល មកឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ ៩០៤៧

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៧ ស្ដីពី ការតម្លើងថ្នាក់ តាមអតីតភាពការងារ ជូនមន្ត្រីរាជការ ចំនួន ០៨ រូប ជាករណីពិសេស ក្នុងឋានន្តស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ របស់ក្រសួងមហាផ្ទៃ ៩០៤៨

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៨ ស្ដីពី ការតម្លើងឋានន្តស័ក្តិតាមអតីតភាពការងារ ជូនមន្ត្រីរាជការ ចំនួន ០២ រូប ពីឋានន្តស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្រប ខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងអភិវឌ្ឍន៍ជនបទ ៩០៤៩

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១០៩៩ ស្ដីពី ការតម្លើងឋានន្តស័ក្តិ ជូនមន្ត្រីរាជការ ០៤ រូប ពីឋានន្តស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៩០៥០

២២-៨-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៨១៤/១១០០ ស្ដីពី ការប្ដូរប្រភេទក្របខ័ណ្ឌ តាមរយៈការប្រឡងប្រជែង ជូនមន្ត្រីរាជការស៊ីវិល ចំនួន ៨០ រូប នៅក្រសួងអភិវឌ្ឍន៍ជនបទ ៩០៥២

០៦-៩-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៩១៤/១១០១ ស្ដីពី ការតែងតាំង ឯកឧត្តម **លី ណារុន** ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ជំនួស ឯកឧត្តម **ប្រាក់ សុខ** ដែលបានទទួលមរណភាព ៩០៥៦

០៦-៩-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៩១៤/១១០២ ស្ដីពី ការតែងតាំង ឯកឧត្តម **ស៊្រុន តារា** ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ៩០៥៧

០៦-៩-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៩១៤/១១០៣ ស្ដីពី ការតែងតាំងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងនីតិកាល ៥ នៃរដ្ឋសភា ចំនួន ០៣ រូប ៩០៥៨

០៦-៩-២០១៤ -ព្រះរាជក្រឹត្យ នស/រកត/០៩១៤/១១០៤ ស្ដីពី ការតែងតាំងជាទីប្រឹក្សាក្រសួងកិច្ចការនារី មានឋានៈស្មើ អគ្គនាយក ចំនួន ០២ រូប ៩០៥៩

## II. រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ

១៩-៩-២០១៤ -អនុក្រឹត្យលេខ ២៥៨ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ពន្ធ័នឹងពាណិជ្ជកម្ម ៩០៦០

១៩-៩-២០១៤ -អនុក្រឹត្យលេខ ២៥៩ អនក្រ.បក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា ៩០៦៩

១៩-៩-២០១៤ -អនុក្រឹត្យលេខ ២៦០ អនក្រ.បក ស្ដីពី ការប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា ឱ្យទៅជាវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា ៩០៧៥

២៥-៩-២០១៤ -អនុក្រឹត្យលេខ ២៦១ អនក្រ.បក ស្ដីពី ការបង្កើតមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ៩០៨០

២៦-៩-២០១៤ -អនុក្រឹត្យលេខ ២៦២ អនក្រ.បក ស្ដីពី ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ៩០៨៤

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦២ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៩០៨៩

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៣ អនក្រ.តត ស្ដីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល ៩០៩០

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៤ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩០៩២

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៥ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ ៩០៩៤

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៦ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៩០៩៦

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៧ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៩០៩៩

២៤-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៨ អនក្រ.តត ស្ដីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៩១០១

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៦៩ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៩១០២

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៧០ អនក្រ.តត ស្ដីពី ការតម្លើងឋានន្តរស័ក្តិ និងប្ដូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការ ៩១០៤

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៧១ អនក្រ.តត ស្ដីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៩១០៦

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៧២ អនក្រ.តត ស្ដីពី ការធ្វើនិយ័តកម្មថ្នាក់មន្ត្រីរាជការតាមអតីតភាពការងារ ៩១០៨

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៣ អនក្រ.តត ស្ដីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៩១១០

២៥-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៤ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់មន្ត្រីរាជការ ៩១១៣
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់ ៩១១៥
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៦ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មថ្នាក់មន្ត្រីរាជការ ៩១១៦
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៧ អនក្រ.តត ស្តីពី ការធ្វើនិយ័តកម្មឋានន្តរស័ក្តិ និងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការតាមអតីតភាពការងារ ៩១១៩
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩១២១
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៧៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៩១២២
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៨០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩១២៤
២៦-៦-២០១៤ -អនុក្រឹត្យលេខ ៩៨១ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៩១២៥
២៧-៦-២០១៤ -អនុក្រឹត្យលេខ ៩៨២ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩១២៦
២៧-៦-២០១៤ -អនុក្រឹត្យលេខ ៩៨៣ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៩១២៧
៣០-៦-២០១៤ -អនុក្រឹត្យលេខ ៩៨៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩១២៨

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៨-៨-២០១៤ -ប្រកាសលេខ ៩៦២ សហវ.ប្រក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃនាយកដ្ឋានត្រួតពិនិត្យកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ៩១២៩
០៩-៩-២០១៤ -សារាចរណែនាំលេខ ០១០ សហវ.អហក ស្តីពី គោលការណ៍ និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៩១៥០

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២២-៧-២០១៤ -ប្រកាសលេខ ០១២៣ ឧស.កឧ.ប្រក.៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន តេហ្វូ តេហ្វូ (ខេមបូឌា) បង្កើតរោងចក្រផលិត កាបូប ៩១៦១
២១-៧-២០១៤ -ប្រកាសលេខ ០១៣៩ ឧស.កឧ.ប្រក.៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ធី អ័រ ស៊ី អេហ្វាម៉ិន បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៩១៦៥
២៩-៧-២០១៤ -ប្រកាសលេខ ០១៤៧ ឧស.កឧ.ប្រក.៧ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វាយ ស្តារ ខតថិន ហ្គាមេន (ខេមបូឌា) លីមីធីត បង្កើតរោងចក្រផលិត សម្លៀកបំពាក់ ៩១៦៩

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម**
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

**ប្រោសព្រះរាជទាន**

**ជាកិច្ចបច្ឆាមរណៈ**

ចំពោះ

សពឯកឧត្តម **ជ័យ សាផុន**

នូវ

គ្រឿងឥស្សរិយយស **ជាតូបការ**

ចារល. ១៤០៩. ១១០៧
**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤*

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
លេខ ...០៤៣/១៤... រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ២២.... ខែ សីហា....ឆ្នាំ ២០១៤
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីឧដ្ឋារ គង់ សំអុល
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៧

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**
ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោក តៃ ចណ្ណថន**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស.១៤០៩.១១០៩

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១៧៦.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ តុលា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៨៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្តតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងឯកឧត្តមឧត្តមសេនីយ៍ឯក **ឃុន សំបូរ** អត្តលេខ ០៦៩៣ ជាទីប្រឹក្សាឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមិនយកប្រាក់បៀវត្សរ៍ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស.១៤០៨.១១០៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤

លេខៈ ១១១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៨១៤/១០៤៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **អែល សំនាង** អត្តលេខ ០១៥០៩ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ រស. ១៤០៥. ១១១០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១២០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **តាំ ឈន** អត្តលេខ ០៣២៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រា.១៤០៤.១១១១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៤*

លេខ: ១១១៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នត្តយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តែងតាំងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា៖

១- ឯកឧត្តម **មិត្ត ការ៉េន** ជាអគ្គលេខាធិការរង

២- ឯកឧត្តម **សួរ ឌិចធំរ** ជាអគ្គលេខាធិការរង

**មាត្រា២:** សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ១១១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

៣៩៧. ១៤០៩. ១១១២

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៤*

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៧

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្ដីសម្រេចលេខ១៥៣ រ.ស ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១២ របស់រដ្ឋសភា ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងឯកឧត្ដម **មាឲ្យ ចិចិត្រ** ជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣ :** សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបាន សម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧នស.១៤០៤.១១១៣

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ថាង ហ្ស៊ាងស៊ី** (TANG SHUANGXI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៦៩ នៅខេត្តហ៊ូណាន សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ថាង ពីវ** (TANG BIAO)។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រស-១៤០៨-១១១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៤*

លេខ:១១៦៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ[illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អាលិកហ្សង់ឌ័រ វ៉ាង** (ALEXANDER WANG) ជនជាតិឥណ្ឌូនេស៊ី សញ្ជាតិឥណ្ឌូនេស៊ី កើតថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧៤ នៅខេត្តស៊ីងកាវ៉ាង សាធារណរដ្ឋឥណ្ឌូនេស៊ី។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១៤០៤. ១១១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១១៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តម្លើងឋានន្តរស័ក្តិ**នាយឧត្តមសេនីយ៍** ជូនឯកឧត្តមឧត្តមសេនីយ៍ឯក **កង សុខន** អត្តលេខ ០៣៣៨ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧រស. ១៤០៩. ១១១៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១៧៨ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ប្តូរប្រភេទក្របខ័ណ្ឌ ជូនមន្ត្រីរាជការ ០២ រូប ជាករណីពិសេស ពីឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ និងពីឋានន្តរស័ក្តិលេខាធិការរដ្ឋបាលដើមខ្សែ នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាល មកឋានន្តរស័ក្តិអនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ៖

១- លោក **ឡុង គីមហុង** ពីក្រមការ ថ្នាក់លេខ ៨ មកអនុមន្ត្រី ថ្នាក់លេខ ១១

២- លោក **សែម សាឡឿន** ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ មកអនុមន្ត្រី ថ្នាក់លេខ ១៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១ល.១៤០៥.១១១៧

លេខ: ១៦២២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង , ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤*

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តម្លើងថ្នាក់ តាមអតីតភាពការងារ ជូនមន្ត្រីរាជការ ចំនួន ៨ រូប ជាករណីពិសេស ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ របស់ក្រសួងមហាផ្ទៃ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **អ៊ាន់ ឌុន** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២- លោក **ឆី គីមតុក** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៣ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ៣- ឯកឧត្តម **កែវ ធី** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ៤- ឯកឧត្តម **សន អ៊ិនថរ** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ២ |
| ៥- ឯកឧត្តម **កែន សត្ថា** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៦- លោក **ស៊ុយ សេរិទ្ធ** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៧- ឯកឧត្តម **នូ លីម** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៨- ឯកឧត្តម **ប៊ុត គីមស៊ាន** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៩ល. ១៤០៤.១១១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤

លេខ: ១១៧៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិតាមអតីតភាពការងារ ជូនមន្ត្រីរាជការ ០២ រូប ពីឋានន្តរស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ក្រសួងអភិវឌ្ឍន៍ជនបទ ៖

១- លោក **ជា ហៀង** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៣

២- លោក **លី សាឌុន** ពីវរមន្ត្រី ថ្នាក់លេខ ១ មកឧត្តមមន្ត្រី ថ្នាក់លេខ ៣

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣ទល.១៤០៨.១១១៩

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤*

លេខ:១១១៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១០៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ០៤ រូប ពីឋានន្តរស័ក្តិវរមន្ត្រី មកឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៖

១- ឯកឧត្តម **តិត សាលី** ពីវរមន្ត្រី ថ្នាក់លេខ ៥ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

២- ឯកឧត្តម **ម៉ុន រដ្ឋា** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៣- ឯកឧត្តម **ឆិត្យ ចន្ថា** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកឧត្តមមន្ត្រី ថ្នាក់លេខ ៥

៤- ឯកឧត្តម **ពុធ សុខា** ពីវរមន្ត្រី ថ្នាក់លេខ ៧ មកឧត្តមមន្ត្រី ថ្នាក់លេខ ៦

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៤០៤.១១២០

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១២៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/១១០០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ប្តូរប្រភេទក្របខ័ណ្ឌតាមរយៈការប្រឡងប្រជែង ជូនមន្ត្រីរាជការស៊ីវិលចំនួន ៨០ រូប នៅក្រសួងអភិវឌ្ឍន៍ជនបទ ៖

ក. ឋានន្តរស័ក្ត អនុមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ចំនួន ៧១ រូប

| | | | |
|---|---|---|---|
| ១ | លោក កា សុធី | ពីនាយក្រមការថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ៩ |
| ២ | លោក កិច្ច មានិត | ពីនាយក្រមការថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ៩ |
| ៣ | លោកស្រី កែវ ដានី | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤ | លោក គង់ គឿន | ពីមន្ត្រីក្រមការថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៥ | លោក គីម តាំងស៊ីន | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦ | លោក គួន ពេជ្រ | ពីមន្ត្រីក្រមការថ្នាក់លេខ ១០ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៧ | លោកឃី ពិសិដ្ឋ | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៨ | លោក ឃឹម សុម៉ាលី | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៩ | លោក ឃួច លីននី | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១០ | លោកស្រី ចាន់ ច្រិប | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១១ | លោក ឆម រង្វា | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១២ | លោកស្រី ជា សុមាលី | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៣ | លោកស្រី ជា សុខនី | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៤ | លោក ឈន ឈឿន | ពីភ្នាក់ងាររដ្ឋបាលថ្នាក់លេខ ៦ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៥ | លោក ឈឹម បុរស | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៦ | លោក ឈឹម សុវណ្ណា | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៤ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៧ | លោក ឈុន សុកា | ពីមន្ត្រីក្រមការថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៨ | លោកស្រី ឈុំ សុខគា | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ១៩ | លោកស្រី ឈូវ ចេងផាសុការី | ពីក្រមការដើមខ្សែ ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២០ | លោកស្រី ឈូ សុខអា | ពីក្រមការដើមខ្សែថ្នាក់លេខ ៦ | ទៅអនុមន្ត្រីថ្នាក់លេខ ១៣ |
| ២១ | លោក ញឹក ឈាង | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៤ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២២ | លោក ថុង ប៊ុនជាង | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៣ | លោក ទី សុវ៉ាត់ថាក់ | ពីលេខាធិការ រដ្ឋបាលដើមខ្សែថ្នាក់លេខ ៦ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៤ | លោក ទឹម ប៊ុនធឿន | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៥ | លោកស្រី ទូច គីមពៅ | ពីនាយក្រមការថ្នាក់លេខ ៣ | ទៅអនុមន្ត្រីថ្នាក់លេខ ៦ |
| ២៦ | លោក ទូច ម៉ាឡា | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១២ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៧ | លោកស្រី ទ្រី គីមលី | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៨ | លោកស្រី ធា ប៊ុនធឿន | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ២៩ | លោក នង ចន្ថា | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣០ | លោក និន ស៊ីណាត | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៣១ | លោក នុត សំភី | ពីមន្ត្រីក្រមការថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣២ | លោក ប៉ុល ចន្ថា | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៣ | លោក ប៉ែន សុភី | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៤ | លោក ប៉ែន សំណាង | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ១០ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៥ | លោក បាន សុធា | ពីមន្ត្រីក្រមការថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៦ | លោកស្រី បែន ចរិយា | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៧ | លោក ប្រាក់ សុវណ្ណ | ពីមន្ត្រីក្រមការថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៨ | លោក ផាន់ សារុន | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៣៩ | លោក ម៉ប់ ជីវិត | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤០ | លោក ម៉ប់ សុផល | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤១ | លោក ម៉ែន វីរៈ | ពីមន្ត្រីក្រមការថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤២ | លោក ម៉ៅ សុខជា | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤៣ | លោក មុំ ចែម | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ១០ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤៤ | លោក យន់ សារ៉ោម | ពីនាយក្រមការថ្នាក់លេខ ២ | ទៅអនុមន្ត្រីថ្នាក់លេខ ៤ |
| ៤៥ | លោក យស ស៊ីមករា | ពីមន្ត្រីក្រមការថ្នាក់លេខ ១២ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤៦ | លោក យូរ វៀរក្ស | ពីមន្ត្រីក្រមការថ្នាក់លេខ ៣ | ទៅអនុមន្ត្រីថ្នាក់លេខ ១៣ |
| ៤៧ | លោកស្រី សន សុផល | ពីក្រមការដើមខ្សែថ្នាក់លេខ ៦ | ទៅអនុមន្ត្រីថ្នាក់លេខ ១៣ |
| ៤៨ | លោក សយ គា | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៤៩ | លោក ស៊ឹង សារស់ | ពីមន្ត្រីក្រមការថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥០ | លោក ស៊ិន សុផា | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥១ | លោក សារី សុខុម | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥២ | លោក សាឯម ភូម៉ា | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥៣ | លោក សុខ ភក្តី | ពីភ្នាក់ងាររដ្ឋបាលថ្នាក់លេខ ៤ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥៤ | លោក សុង ណាំង | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥៥ | លោក សួស បូរិន្ទសក្តិ | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥៦ | លោកស្រី សេង សំអឿន | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៥៧ | លោក ស្រី ចាន់ធឿន | ពីនាយក្រមការថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ៩ |
| ៥៨ | លោកស្រី ស្វាយ សុវណ្ណា | ពីក្រមការដើមខ្សែថ្នាក់លេខ ៤ | ទៅអនុមន្ត្រីថ្នាក់លេខ ១០ |
| ៥៩ | លោកស្រី សំ វ៉ាន | ពីក្រមការដើមខ្សែថ្នាក់លេខ ៧ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦០ | លោក សំ គីមសុង | ពីលេខាធិការរដ្ឋបាលដើមខ្សែ ថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |

| | | | |
|---|---|---|---|
| ៦១ | លោក ហង្ស សាវៃ | ពីក្រមការដើមខ្សែថ្នាក់លេខ ៤ | ទៅអនុមន្ត្រីថ្នាក់លេខ ១០ |
| ៦២ | លោក ឡុក ខ្មៅ | ពីនាយក្រមការថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៣ | លោក ឡុង កុសលវឌ្ឍនៈ | ពីលេខាធិការរដ្ឋបាល ថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦៤ | លោកស្រី អន សាមល | ពីក្រមការដើមខ្សែថ្នាក់លេខ ៨ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦៥ | លោក អ៊ិច ជីវន្ត | ពីក្រមការដើមខ្សែថ្នាក់លេខ ៩ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦៦ | លោក អ៊ឹង ចន្ទសុវណ្ណ | ពីមន្ត្រីក្រមការថ្នាក់លេខ ១២ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦៧ | លោក អ៊ឹង ពន្លា | ពីមន្ត្រីក្រមការថ្នាក់លេខ ១១ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៦៨ | លោក អ៊ិត សំអាង | ពីក្រមការដើមខ្សែថ្នាក់លេខ ៣ | ទៅអនុមន្ត្រីថ្នាក់លេខ ៩ |
| ៦៩ | លោក អ៊ូ សុវណ្ណតារា | ពីភ្នាក់ងាររដ្ឋបាលថ្នាក់លេខ ៥ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |
| ៧០ | លោក អាន ស៊ីណា | ពីក្រមការដើមខ្សែថ្នាក់លេខ ៦ | ទៅអនុមន្ត្រីថ្នាក់លេខ ១៣ |
| ៧១ | លោក អេង ធី | ពីភ្នាក់ងាររដ្ឋបាលថ្នាក់លេខ ៣ | ទៅអនុមន្ត្រីថ្នាក់លេខ ១៤ |

ខ.ឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ចំនួន ០៩ រូប

| | | | |
|---|---|---|---|
| ១ | លោក កែវ ធាយ | ពីភ្នាក់ងារបច្ចេកទេស ថ្នាក់លេខ ៣ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ២ | លោក ចាន់ ពង្សវឌ្ឍនា | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៣ | លោក ចិន ជឹម | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១០ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៤ | លោក ឈា វ៉េងហ៊ុយ | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ១១ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៥ | លោកស្រី ឈី បុព្វ | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៦ | លោក ម៉ា សាផាន | ពីមន្ត្រីបច្ចេកទេសបឋមដើមខ្សែពិសេស ថ្នាក់លេខ ១ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៧ | លោក លន់ សាយតេង | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៨ | លោក សែម ចន្ទនី | ពីមន្ត្រីបច្ចេកទេសមធ្យម ថ្នាក់លេខ ៨ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |
| ៩ | លោក អ៊ឹង សេរ៉ាមី | ពីមន្ត្រីបច្ចេកទេសមធ្យមដើមខ្សែ ថ្នាក់លេខ ៩ | ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១៤ |

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស.រកត.០៨១៤.១១២១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៤*

លេខៈ ១១២៥ ស.ណ

**សំណៅដែលមានអង្គលេខាការចែកផ្សាយ**

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/១១០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចំនួន ០១រូប នាថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤
- បានទ្រង់យល់សំណើរបស់ឯកឧត្តម **សាយ ឈុំ** ប្រធានស្តីទីព្រឹទ្ធសភា ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង **ឯកឧត្តម លី ណារុន** ជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ជំនួស **ឯកឧត្តម ប្រាក់ សុខ** ដែលបានទទួលមរណភាព ។

**មាត្រា២ :** ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ការ. ១៤០៩. ១១២២

លេខ: ១១៧៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/ ១១០២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងឯកឧត្តម **ស្រ៊ុន តារា** ជា**អគ្គលេខាធិការរង** នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចរា. ១៤០៩. ១១២៣

លេខ: ១១៤២ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/១១០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ត្រូវបានតែងតាំងអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា :

១- ឯកឧត្តម **ហ៊ុល ម៉ិនថា** **អគ្គលេខាធិការរង**
២- ឯកឧត្តម **ហ៊ីង សុខសាន្ត** **អគ្គលេខាធិការរង**
៣- ឯកឧត្តម **កែត ឃី** **អគ្គលេខាធិការរង**

**មាត្រា២ :** សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

៣៣៧. ១៤០៩. ១១៤៤

លេខៈ ១១៤៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៩១៤/១១០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងជា**ទីប្រឹក្សាក្រសួងកិច្ចការនារី** មានឋានៈស្មើ **អគ្គនាយក** ចំនួន ០២ រូប :

១- លោកជំទាវ **លឹម ប៊ុនលី**

២- លោកជំទាវ **ឡិ សុខុម**

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៤*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

ការ. ១៤០៧. ១១២៥

**ហត្ថលេខា និងព្រះរាជលញ្ចករ**
**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ១១៣៤ ស.ណ
**សំណៅដែលមានអធិប្បាយជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ នៃនិយ័តដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតឡើងនូវនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដែលសរសេរជាអក្សរកាត់ថា **ន.ជ.ព.ព.** ស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងប្រមូលផ្តុំ រក្សាទុកព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មក្នុងទម្រង់ទន់និងទម្រង់រឹង និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដល់សាធារណជន។

**មាត្រា៣.-**

វាក្យសព្ទបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចមានចែងក្នុងឧបសម្ព័ន្ធ។

## ជំពូកទី២

## សមាសភាពនិងភារកិច្ចរបស់ ន.ជ.ព.ព.

**មាត្រា៤.-**

**ន.ជ.ព.ព.** មានសមាសភាពដឹកនាំដូចខាងក្រោម៖

| | |
|---|---|
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - តំណាងក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងក្រសួងការពារជាតិ | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងផែនការ | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |

- តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន                                    សមាជិក
- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ                                    សមាជិក
- តំណាងក្រសួងរ៉ែនិងថាមពល                                    សមាជិក
- តំណាងក្រសួងទេសចរណ៍                                    សមាជិក
- តំណាងធនាគារជាតិនៃកម្ពុជា                                    សមាជិក
- តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល                                    សមាជិក
- តំណាងសភាពាណិជ្ជកម្មកម្ពុជា                                    សមាជិក។

សមាសភាពជាក់ស្តែងនៃ **ន.ជ.ព.ព.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥ .-**

**ន.ជ.ព.ព.** មានភារកិច្ចដូចតទៅ៖

- ប្រមូលផ្តុំនិងរក្សាទុកព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មក្នុងទម្រង់ទន់និងទម្រង់រឹង  ដើម្បីបញ្ចូលទៅក្នុងគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ត្រូវផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដល់សាធារណជន និងធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវព័ត៌មានទាំងនោះឱ្យបានទាន់ពេលវេលា
- អនុញ្ញាតឱ្យសាធារណជនអាចស្វែងរកបានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- រក្សាសិទ្ធិពន្យារការដាក់បញ្ចូលព័ត៌មានដែលទទួលបានពីក្រសួង  ស្ថាប័នពាក់ព័ន្ធក្នុងករណីដែលព័ត៌មានទាំងនោះមិនស្របទៅនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីនិងកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនានាដែលព្រះរាជាណាចក្រកម្ពុជាជាភាគី
- រាយការណ៍ពីការពន្យារការដាក់បញ្ចូលព័ត៌មានជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ  ដើម្បីសុំការណែនាំនិងឆ្លើយតបទៅស្ថាប័នពាក់ព័ន្ធវិញ និង
- តភ្ជាប់គេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មជាមួយគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាណិជ្ជកម្មនានានៃរដ្ឋសមាជិកអាស៊ាននដទៃទៀត  ដើម្បីឈានទៅបង្កើតគេហទំព័រនិហិតដ្ឋានអាស៊ានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។

**មាត្រា៦ .-**

**ន.ជ.ព.ព.** មានសិទ្ធិស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធផ្តល់ព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។ ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវ៖

- ចាត់ក្រុមមន្ត្រីទំនាក់ទំនងរបស់ខ្លួនដើម្បីផ្តល់ព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដូចមានចែងក្នុងមាត្រា៨ទៅលេខាធិការដ្ឋាន  ធ្វើបច្ចុប្បន្នកម្មឈ្មោះក្រុមមន្ត្រីទំនាក់ទំនងរៀងរាល់ខែ និងជូនដំណឹងជាបន្ទាន់ក្នុងករណីមានការផ្លាស់ប្តូរក្រុមមន្ត្រីទំនាក់ទំនងមកលេខាធិការដ្ឋាន ។

- ត្រូវផ្តល់ព័ត៌មានអំពីការកែប្រែព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដូចមានចែងក្នុងមាត្រា៨តាមរយៈក្រុមមន្ត្រីទំនាក់ទំនង
- ផ្តល់ព័ត៌មានជាមុនទៅលេខាធិការដ្ឋានអំពីផែនការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ផ្តល់ព័ត៌មានជាបន្ទាន់ទៅលេខាធិការដ្ឋាន ក្នុងករណីរកឃើញថាព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលបានផ្តល់ឱ្យមានលក្ខណៈមិនត្រឹមត្រូវ មិនពេញលេញ ឬអស់សុពលភាព
- ផ្តល់ព័ត៌មានជាភាសាខ្មែរនិងអង់គ្លេសក្នុងទម្រង់ទន់និងទម្រង់រឹងទៅលេខាធិការដ្ឋានដើម្បីដាក់បញ្ចូលទៅក្នុងគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ទទួលបន្ទុករៀបចំមេតាទិន្នន័យដែលងាយស្រាវជ្រាវនិងទាញយកឯកសារនីមួយៗ និង
- ឆ្លើយតបទៅនឹងសំណួររបស់អ្នកប្រើគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមរយៈលេខាធិការដ្ឋាន។

**មាត្រា៧ ..-**

សមាជិក **ន.ជ.ព.ព.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីចាំបាច់ ប្រធាន **ន.ជ.ព.ព.** អាចកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតឱ្យចូលរួមប្រជុំបាន។

**ន.ជ.ព.ព.** មានសិទ្ធិប្រើត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីសម្រួលការងារ។

## ជំពូកទី៣
## សមាសភាគនៃព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម

**មាត្រា៨ ..-**

សមាសភាគនៃព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មដែលត្រូវបញ្ចូលក្នុងគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម មានដូចខាងក្រោម៖

- តារាងនាមវលី
- តារាងពន្ធប្រជាជាតិអនុគ្រោះបំផុត
- តារាងពន្ធចងរបស់កម្ពុជាក្រោមអង្គការពាណិជ្ជកម្មពិភពលោក
- កម្មវិធីកាត់បន្ថយនិងលុបពន្ធនាំចូលក្រោមកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីនានា
- វិធានដើមកំណើតទំនិញ
- វិធានការមិនមែនពន្ធ
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាណិជ្ជកម្ម
- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តគយ
- នីតិវិធីនិងឯកសារតម្រូវ
- សេចក្តីសម្រេចរដ្ឋបាល
- ការអនុវត្តល្អនូវការសម្រួលពាណិជ្ជកម្ម

- បញ្ជីពាណិជ្ជករដែលបានទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការពាណិជ្ជកម្ម និង
- ព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មផ្សេងៗទៀត។

## ជំពូកទី៤
## លេខាធិការដ្ឋាន ន.ជ.ព.ព.

**មាត្រា៩ .-**

**ន.ជ.ព.ព.** មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោមៈ

- ប្រធាននាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាននៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ប្រធាន
- មន្ត្រីបច្ចេកទេសនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយចំនួន សមាជិក

លេខាធិការដ្ឋាន **ន.ជ.ព.ព.** មានទីតាំងនៅនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ចនិងអាស៊ាននៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០ .-**

លេខាធិការដ្ឋានមានភារកិច្ច ដូចខាងក្រោមនេះៈ

- ចាត់តាំងក្រុមមន្ត្រីគាំទ្រដំណើរការនៃ **ន.ជ.ព.ព.**
- ស្រាវជ្រាវនិងទទួលព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងពីប្រភពអន្តរជាតិដើម្បីរៀបចំដាក់បញ្ចូល ព្រមទាំងធ្វើបច្ចុប្បន្នកម្មជាប្រចាំនូវព័ត៌មានទាំងនោះឱ្យបានទាន់ពេលវេលាទៅក្នុងគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ទទួលសំណួរពីអ្នកប្រើប្រាស់គេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងជូនព័ត៌មានទៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីឆ្លើយតបតាមវិស័យទទួលខុសត្រូវរៀងៗខ្លួន
- ទទួលយោបល់ពីអ្នកប្រើប្រាស់គេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីកែលម្អឱ្យកាន់តែប្រសើរឡើងនូវដំណើរការគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
- ធានានិរន្តរភាពដំណើរការគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដើម្បីទ្រទ្រង់ការប្រើប្រាស់ ជាប្រចាំដោយសាធារណជន
- ការពារគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ពីការបំផ្លិចបំផ្លាញពីខាងក្រៅ
- រាយការណ៍រៀងរាល់ត្រីមាសជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីដំណើរការ **ន.ជ.ព.ព.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធាន **ន.ជ.ព.ព.**

## ជំពូកទី៥
## ប្រភពធនធាននិងមូលនិធិ

**មាត្រា១១ .-**

ការចំណាយសម្រាប់ដំណើរការ **ន.ជ.ព.ព.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ន.ជ.ព.ព.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការនៃ **ន.ជ.ព.ព.**។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧៥៧. អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា. ឆ្នាំ២០១៤**
**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម**
**និយមន័យនៃពាក្យសព្ទបច្ចេកទេស**

- **និហិតដ្ឋាន** (Repository) សំដៅដល់កន្លែងរក្សាទុកព័ត៌មាន។
- **តារាងនាមវលី** (Tariff Nomenclature) សំដៅដល់បញ្ជីឬតារាងរៀបរាប់ឈ្មោះទំនិញ។
- **ប្រព្រឹត្តកម្មប្រជាជាតិអនុគ្រោះបំផុត** (Most Favored Nations) សំដៅដល់ប្រព្រឹត្តកម្ម អនុគ្រោះបំផុត ផ្នែកពន្ធនៅក្រោមអង្គការពាណិជ្ជកម្មពិភពលោកដូចមានចែងខាងក្រោមនេះ៖

១- ចំពោះពន្ធនាំចូលនិងបន្ទុកគ្រប់ប្រភេទដែលបានដាក់ឬពាក់ព័ន្ធដល់ការនាំចូលនិងការនាំចេញ ឬដែលបានដាក់លើការផ្ទេរ ការទូទាត់អន្តរជាតិ សម្រាប់ការនាំចូលឬការនាំចេញ និងចំពោះវិធីនៃការយកពន្ធនាំចូល និងបន្ទុកទាំងនោះ និងចំពោះរាល់វិធាននិងបែបបទពាក់ព័ន្ធនឹងការនាំចូលនិងការនាំចេញនិងចំពោះបញ្ហាដែលមានចែងនៅក្នុងកថាខណ្ឌ២និង៤នៃមាត្រា III ផលប្រយោជន៍ ការអនុគ្រោះ បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិដែលបានផ្តល់ដោយភាគីនៃកិច្ចសន្យា ទៅឱ្យរាល់ផលិតផលដែលមានដើមកំណើតនៅក្នុងឬឆ្ពោះទៅប្រទេសដទៃទៀត ត្រូវបានផ្តល់ជាបន្ទាន់និងគ្មានលក្ខខណ្ឌទៅឱ្យផលិតផលដូចគ្នាដែលមានដើមកំណើតនៅក្នុងឬឆ្ពោះទៅដែនដីនៃភាគីហត្ថលេខីដទៃទៀត។

២-បទប្បញ្ញត្តិទាំងឡាយនៃកថាខណ្ឌ១នៃមាត្រានេះ មិនតម្រូវឱ្យមានការលុបការអនុគ្រោះណាមួយចំពោះពន្ធនាំចូលឬបន្ទុកនានាដែលមិនហួសកម្រិតដូចមានចែងក្នុងកថាខណ្ឌ៤នៃមាត្រានេះនិងដែលស្ថិតក្នុងចំណោមការពិពណ៌នាខាងក្រោម៖

(ក) ការអនុគ្រោះជាធរមានសម្រាប់តែរវាងដែនដីពីរឬច្រើនដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក ស្ថិតក្រោមលក្ខខណ្ឌដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ក

(ខ) ការអនុគ្រោះជាធរមានសម្រាប់តែរវាងដែនដីពីរឬច្រើននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៣៩ ដែលពាក់ព័ន្ធនឹងអធិបតេយ្យភាពរួមឬទំនាក់ទំនងក្នុងការការពារឬអាណានិគម និងដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ខ គ និង ឃ ស្ថិតក្រោមលក្ខខណ្ឌដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ខ គ និង

(គ) ការអនុគ្រោះជាធរមានសម្រាប់តែរវាងសហរដ្ឋអាមេរិកនិងសាធារណរដ្ឋគុយបា

(ឃ) ការអនុគ្រោះជាធរមានរវាងបណ្តាប្រទេសជិតខាងដែលមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ង និង ច

៣-បទប្បញ្ញត្តិទាំងឡាយនៃកថាខណ្ឌ១ មិនត្រូវអនុវត្តទៅលើការអនុគ្រោះរវាងប្រទេសទាំងឡាយដែលពីមុនជាផ្នែកមួយនៃចក្រភព អូតូម៉ង់ និងដែលបានផ្តាច់ចេញពីចក្រភពនោះ [illegible]

ខែកក្កដា ឆ្នាំ១៩២៣ ដរាបណាការអនុគ្រោះទាំងនោះ ត្រូវបានយល់ព្រមក្រោមកថាខណ្ឌ៥[១] នៃមាត្រា XXV ដែលត្រូវបានអនុវត្តចំពោះបញ្ហានេះដោយផ្អែកលើកថាខណ្ឌ១នៃមាត្រា XXIX។

៤-កម្រិតនៃការអនុគ្រោះផលិតផលទាំងឡាយដែលការអនុគ្រោះណាមួយដែលត្រូវបានអនុញ្ញាតក្រោមកថាខណ្ឌទី២នៃមាត្រានេះ ប៉ុន្តែមិនបានចែងជាក់លាក់ជាកម្រិតអតិបរមានៃការអនុគ្រោះដែលមានក្នុងកម្មវិធីសមស្របដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះមិនត្រូវលើសៈ

(ក) ចំពោះពន្ធនាំចូលនិងបន្ទុកនានាទៅលើផលិតផលណាមួយដែលបានរៀបរាប់នៅក្នុងកម្មវិធីភាពខុសគ្នារវាងពន្ធប្រជាជាតិអនុគ្រោះបំផុតនិងពន្ធអនុគ្រោះដែលមានចែងនៅក្នុងកម្មវិធី ប្រសិនបើគ្មានពន្ធអនុគ្រោះត្រូវបានចែង ពន្ធអនុគ្រោះដែលត្រូវយកមកប្រើសម្រាប់គោលបំណងនៃកថាខណ្ឌនេះត្រូវតែជាពន្ធអនុគ្រោះដែលជាធរមាននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧ និងបើគ្មានពន្ធប្រជាជាតិអនុគ្រោះត្រូវបានចែង កម្រិតអនុគ្រោះមិនត្រូវលើសភាពខុសគ្នារវាងពន្ធប្រជាជាតិអនុគ្រោះបំផុតនិងពន្ធអនុគ្រោះដែលមាននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧។

(ខ) ចំពោះពន្ធនាំចូលនិងបន្ទុកនានាទៅលើផលិតផលណាមួយដែលមិនបានរៀបរាប់នៅក្នុងកម្មវិធីសមស្រប ភាពខុសគ្នារវាងពន្ធប្រជាជាតិអនុគ្រោះបំផុត និងពន្ធអនុគ្រោះដែលមាននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧។

ក្នុងករណីដែលភាគីហត្ថលេខីមានរាយនាមក្នុងឧបសម្ព័ន្ធ ធ ចុះកាលបរិច្ឆេទថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៤៧ ដែលមានចែងនៅក្នុងវាក្យខណ្ឌ (ក) និង (ខ) នៃកថាខណ្ឌនេះ ត្រូវជំនួសដោយកាលបរិច្ឆេទដែលមានចែងក្នុងឧបសម្ព័ន្ធទាំងនោះ។

- **តារាងពន្ធប្រជាជាតិអនុគ្រោះបំផុត** (Most Favored Nations Tariff) សំដៅដល់ពន្ធនាំចូលដែលប្រទេសសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកផ្តល់ឱ្យគ្នាទៅវិញទៅមកដោយគ្មានការរើសអើង។
- **ពន្ធចង** (Bound Rate) សំដៅដល់ពន្ធខ្ពស់បំផុតដែលបានសន្យានៅពេលចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។
- **ក្រសួង ស្ថាប័នពាក់ព័ន្ធ** សំដៅដល់ក្រសួង ស្ថាប័ន ដែលគ្រប់គ្រងសមាសភាគនៃព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។
- **វិធានដើមកំណើតទំនិញ** (Rules of Origin) សំដៅដល់វិធានដែលកំណត់លក្ខណវិនិច្ឆ័យទំនិញដែលមានដើមកំណើតពីភាគីនៃកិច្ចព្រមព្រៀងនិងនីតិវិធីប្រតិបត្តិ។
- **វិធានការមិនមែនពន្ធ** (Non-Tariff Measures) សំដៅដល់គោលនយោបាយក្រៅពីពន្ធដែលអាចប៉ះពាល់ដល់ពាណិជ្ជកម្មអន្តរជាតិ។

---

[១] អត្ថបទត្រឹមត្រូវតាមច្បាប់អានដោយភាន់ច្រឡំថាជា "វាក្យខណ្ឌ ៥ (ក)"

- **នីតិវិធីនិងឯកសារតម្រូវ** (Procedures and Documentary Requirement) សំដៅដល់លិខិតបទដ្ឋានគតិយុត្តក្នុងការអនុវត្តច្បាប់ ព្រមទាំងឯកសារចាំបាច់ដែលត្រូវភ្ជាប់មកជាមួយ។
- **សេចក្តីសម្រេចរដ្ឋបាល** (Administrative Ruling) សំដៅដល់ការសម្រេចនានាសម្រាប់ការអនុវត្តទូទៅដែលពាក់ព័ន្ធនឹងពាណិជ្ជកម្មរបស់រដ្ឋបាលសាធារណៈ។
- **មេតាទិន្នន័យ** (Meta-Data) សំដៅដល់ពាក្យគន្លឹះសម្រាប់ស្វែងរកព័ត៌មានដែលមាននៅក្នុងគេហទំព័រ។
- **គេហទំព័រនៃនិយតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម** សំដៅដល់ទីផ្ទុកព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកហើយមានអាសយដ្ឋាន ntr.moc.gov.kh ។/៕

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១០/០០៩ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក
- បានឃើញអនុក្រឹត្យលេខ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៤/

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតឡើងនូវគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **គ.ស.ន.ម.ក.** ដើម្បីសម្របសម្រួលនិងជានាប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក។

**មាត្រា២ .-**

វាក្យសព្ទបច្ចេកទេស ដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចមានចែងក្នុងឧបសម្ព័ន្ធ។

## ជំពូកទី២

## សមាសភាពរបស់ គ.ស.ន.ម.ក.

**មាត្រា៣ .-**

**គ.ស.ន.ម.ក.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងការពារជាតិ | សមាជិក |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងយុត្តិធម៌ | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| - តំណាងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| - តំណាងអភិបាលនៃគណៈអភិបាលរាជធានី ខេត្តពាក់ព័ន្ធ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានដឹកជញ្ជូន | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **គ.ស.ន.ម.ក.** ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទីនិងភារកិច្ច

**មាត្រា៤ .-**

**គ.ស.ន.ម.ក.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ជំរុញការអនុវត្តកិច្ចព្រមព្រៀងនិងជានាសេរីភាពនាវាចរណ៍ ដោយធ្វើឱ្យមានភាពស៊ីចង្វាក់គ្នានូវបទបញ្ជាទាំងឡាយ ជាអាទិ៍ សុវត្ថិភាពនាវាចរណ៍ កណ្តាលជារកិច្ច តារាងកម្រងតម្លៃសេវា សញ្ញាជំនួយនាវាចរណ៍ សេវាចរាចរណ៍នាវា ការដឹកជញ្ជូនទំនិញ អ្នកដំណើរ ការរុករកនិងសង្គ្រោះ ការបង្ការទប់ស្កាត់ការបំពុលពីនាវា ការស៊ើបអង្កេតនាវា បច្ចេកទេសពិនិត្យ អង្កេតផ្លូវទឹក បទដ្ឋាននៃការបណ្តុះបណ្តាល និងសមត្ថភាពជំនាញ ការប្រើប្រាស់ និងប្រតិបត្តិការនៃអង្គបណ្តែត គយ អន្តោប្រវេសន៍ សុខាភិបាល និងបរិស្ថាន
- សម្របសម្រួលរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច ផ្នែកឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវទឹក
- សម្របសម្រួលការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ស្របតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នមានសមត្ថកិច្ច ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងប្រទេសផ្សេងទៀត ដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមផ្លូវទឹកជាមួយព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យនិងលើកសំណើកែសម្រួល ឬធ្វើវិសោធនកម្មកិច្ចព្រមព្រៀង
- ធ្វើរបាយការណ៍អំពីដំណើរការនិងសកម្មភាពអនុវត្តការងាររបស់**គ.ស.ន.ម.ក.** ជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ស.ន.ម.ក.

**មាត្រា៥ .-**

**គ.ស.ន.ម.ក.** ត្រូវធ្វើកិច្ចប្រជុំរបស់ខ្លួនយ៉ាងតិច១(មួយ)ដងក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

**មាត្រា៦ .-**

**គ.ស.ន.ម.ក.** អាចស្នើសុំអញ្ជើញតំណាងក្រសួង ស្ថាប័ន ផ្នែកឯកជន ឬអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់អំពីការងារជាក់លាក់ណាមួយ ដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀង។

**គ.ស.ន.ម.ក.** អាចអញ្ជើញអ្នកជំនាញការជាតិនិងអន្តរជាតិ ចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ ដើម្បីកែលម្អ ឬដើម្បីធ្វើឱ្យទំនើបការដឹកជញ្ជូនតាមផ្លូវទឹក។

**មាត្រា៧ .-**

បែបបទនិងនីតិវិធីការងាររបស់ **គ.ស.ន.ម.ក.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ គ.ស.ន.ម.ក.

**មាត្រា៨ .-**

**គ.ស.ន.ម.ក.** មានសិទ្ធិបង្កើតគណៈកម្មការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់តាមការចាំបាច់ដើម្បីជួយបំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

សមាសភាពនិងតួនាទីភារកិច្ចរបស់គណៈកម្មការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ន.ម.ក.**។

**មាត្រា៩ .-**

**គ.ស.ន.ម.ក.** មានលេខាធិការដ្ឋានមួយជាសេនាធិការ នៅអគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការនិងដឹកជញ្ជូន។

លេខាធិការដ្ឋានរបស់ **គ.ស.ន.ម.ក.** ត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរបស់ **គ.ស.ន.ម.ក.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

លេខាធិការដ្ឋាននេះមានមន្ត្រីជំនាញមកពីក្របខ័ណ្ឌនៃក្រសួងសាធារណការនិងដឹកជញ្ជូន។

**មាត្រា១០ .-**

**គ.ស.ន.ម.ក.** មានសិទ្ធិប្រើត្រារបស់ក្រសួងសាធារណការនិងដឹកជញ្ជូនដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាននិងមូលនិធិ

**មាត្រា១១ .-**

ការចំណាយសម្រាប់ដំណើរការ **គ.ស.ន.ម.ក.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។

**គ.ស.ន.ម.ក.** មានសិទ្ធិទទួលនិងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។/.

**មាត្រា១៣ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ
## នៃអនុក្រឹត្យលេខ២៥៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤
## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ
## នៃគណៈកម្មាធិការសម្របសម្រួលនាវាចរណ៍មេគង្គកម្ពុជា

### វាក្យសព្ទបច្ចេកទេស

***ការរុករកនិងសង្គ្រោះ*** (Search and Rescue) សំដៅដល់ការស្វែងរកជំនួយសង្គ្រោះមនុស្ស ដែលកំពុងស្ថិតនៅក្នុងភាពអាសន្នឬកំពុងស្ថិតនៅក្នុងភាពគ្រោះថ្នាក់។

***កណ្តូបការកិច្ច*** (Pilotage) សំដៅដល់សកម្មភាពដែលធ្វើឡើងដោយកណ្តូបការក្នុងការជួយដល់មេបញ្ជាការនាវាឬបរិបាលនាវា ដើម្បីបើកបរនាវា នៅពេលចូលនិងចេញពីកំពង់ផែ។

***កណ្តូបការ*** (Pilot) ជាបុគ្គលដែលមានគុណវុឌ្ឍិឬសមត្ថភាពវិជ្ជាជីវៈសមស្រប ជួយដល់មេបញ្ជាការនាវាឬបរិបាលនាវា ដើម្បីបើកបរនាវា នៅពេលចូលនិងចេញពីកំពង់ផែ។

***កិច្ចព្រមព្រៀង*** (Agreement) សំដៅដល់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក។

***អង្គបណ្តែតទឹក*** (Floating Structure) សំដៅដល់សំណង់បណ្តែតទឹក ដែលមិនត្រូវបានយកទៅប្រើប្រាស់ជាសំខាន់ទុកជាមធ្យោបាយដឹកជញ្ជូនលើទឹកទេ ប៉ុន្តែត្រូវបានយកទៅប្រើប្រាស់សម្រាប់គោលបំណងពាណិជ្ជកម្មផ្សេងទៀត ដូចជាកន្លែងស្តុកទំនិញឬចំណត កន្លែងខួងរ៉ែ កន្លែងសំណង់ ឬកន្លែងជួសជុលនាវា ដងស្ទូច កញ្ចូមប្រេង ការដឹកស្ពានឬខ្សឿរ ដោយលើកលែងតែចំពោះអង្គបណ្តែតទឹកណាដែលប្រើប្រាស់ជាផ្ទះ លំនៅឋាន កន្លែងពាណិជ្ជកម្ម ឬការិយាល័យ។

***សុវត្ថិភាពនាវាចរណ៍*** (Safe Navigation of Ships) សំដៅដល់ការធ្វើដំណើររបស់នាវាប្រកបដោយសេចក្តីសុខ គ្មានគ្រោះថ្នាក់ គ្មានការគម្រាមកំហែងកើតឡើងចំពោះនាវា នាវិក ឬមនុស្សដែលស្ថិតនៅលើនាវា ឬធ្វើនាវាចរណ៍ប្រកបដោយសុវត្ថិភាព។ ក្នុងបរិបទនេះ សុវត្ថិភាពនាវាចរណ៍ត្រូវមានចំណុចសំខាន់ៗដូចខាងក្រោមៈ

- សុវត្ថិភាពនាវា ដែលរួមមានផ្នែកសំខាន់ៗនៃនាវា ជាអាទិ៍ រចនាសម្ព័ន្ធរូបវន្តរបស់នាវា ម៉ាស៊ីននាវា និងនាវូបករណ៍
- លក្ខណៈបច្ចេកទេសរបស់នាវា ដែលពាក់ព័ន្ធនឹងវិធានការសន្តិសុខនិងវិធានការបង្ការការបំពុលបរិស្ថានដែលមានប្រភពពីនាវា
- មេបញ្ជាការនាវា បរិបាលនាវា ឬក្រុមនាវិក ដែលមានគុណវុឌ្ឍិឬសមត្ថភាពវិជ្ជាជីវៈគ្រប់គ្រាន់ក្នុងការបើកបរនាវាប្រកបដោយសុវត្ថិភាព។

***អ្នកដំណើរ*** (Passenger) សំដៅដល់បុគ្គលណាម្នាក់ដែលធ្វើដំណើរនៅលើនាវា តែមិនមែនជាសមាជិកនាវិក និងមានឈ្មោះនៅក្នុងបញ្ជីអ្នកដំណើរ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា ឲ្យទៅជាវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌាឲ្យទៅជា វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា Cambodia-India Entrepreneurship Development Institute ដែលសរសេរជាអក្សរកាត់ថា **វ.អ.ស.ក.ឥ.** និងជាអក្សរឡាតាំងថា C.I.E.D.I.។ វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌានេះមានឋានៈស្មើនាយកដ្ឋាន ស្ថិតនៅក្រោមឱវាទក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងមានទីតាំងស្ថិតនៅតាមបណ្តោយមហាវិថីសហព័ន្ធរុស្ស៊ី ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

**មាត្រា២ .-**

វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌាមានភារកិច្ចៈ

- បណ្តុះបណ្តាលផ្នែកសហគ្រិនគ្រប់កម្រិត រួមមាន វគ្គខ្លី បឋម មធ្យម និងឧត្តម
- បណ្តុះបណ្តាលគ្រូផ្នែកសហគ្រិន
- ផ្តល់សេវាពិគ្រោះយោបល់ក្នុងការធ្វើជំនួញ
- ស្រាវជ្រាវនិងរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលសហគ្រិន
- ជួយគាំទ្រដល់សិស្ស និស្សិត ដែលបានបញ្ចប់ការសិក្សានៅ **វ.អ.ស.ក.ឥ.** ដើម្បីអភិវឌ្ឍសហគ្រាស
- ផ្តល់ចំណេះដឹង ចំណេះធ្វើ និងបច្ចេកទេសដល់សហគ្រិនថ្មីនៅក្នុងការបង្កើតសហគ្រាសថ្មី
- ផ្តល់ការបណ្តុះបណ្តាលផ្នែកភាសាអង់គ្លេសនិងផ្នែកព័ត៌មានវិទ្យា
- ទំនាក់ទំនងជាមួយវិទ្យាស្ថានក្នុងនិងក្រៅប្រទេស អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ ក្រសួង ស្ថាប័ន និងក្រុមហ៊ុននានា ដើម្បីធ្វើឲ្យការបណ្តុះបណ្តាលផ្នែកសហគ្រិនឲ្យកាន់តែមានគុណភាព និងមានប្រសិទ្ធភាពសមស្របទៅនឹងការរីកចម្រើនរបស់ទីផ្សារក្នុងនិងក្រៅប្រទេស
- បណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីតឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីតឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ សិក្សារយៈពេល១ឆ្នាំ មាន៣០ក្រេឌីតឡើងទៅ
- បណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ មាន៦០ក្រេឌីតឡើងទៅ/

- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ មាន១២០ក្រេឌីតឡើងទៅ។

**មាត្រា៣.-**

វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- ការិយាល័យរដ្ឋបាល
២- ការិយាល័យហិរញ្ញវត្ថុ
៣- ការិយាល័យបណ្តុះបណ្តាល
៤- ការិយាល័យទំនាក់ទំនងនិងពិគ្រោះយោបល់ផ្នែកសហគ្រិន
៥- ការិយាល័យផែនការ
៦- ការិយាល័យបច្ចេកទេស
៧- ការិយាល័យបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
៨- ការិយាល័យធានាគុណភាពផ្ទៃក្នុង
៩- ដេប៉ាតឺម៉ង់គ្រប់គ្រងនិងសហគ្រិនភាព
១០- ដេប៉ាតឺម៉ង់ព័ត៌មាននិងវិស្វកម្ម
១១- ដេប៉ាតឺម៉ង់គណនេយ្យនិងហិរញ្ញវត្ថុ
១២- ដេប៉ាតឺម៉ង់ភាសាបរទេស
១៣- ដេប៉ាតឺម៉ង់ម៉ាឃីតធីង

វិទ្យាស្ថាននេះអាចបើកដេប៉ាតឺម៉ង់ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៤.-**

លក្ខខណ្ឌទទួលសិស្ស និស្សិតឲ្យចូលរៀន៖

- កម្រិតវិញ្ញាបនបត្របណ្តុះបណ្តាលវិជ្ជាជីវៈ បេក្ខជនជាសិក្ខាកាម សិស្ស និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ បេក្ខជនបានរៀនចប់ថ្នាក់ទី៩នៃមធ្យមសិក្សាបឋមភូមិឬវិញ្ញាបនបត្រស្គាល់ចម្លងបន្តជំនាញ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ ចំពោះបេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ ចំពោះបេក្ខជនដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២
- កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស បេក្ខជនមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ ឬប្រឡងជាប់ ឬប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឬសញ្ញាបត្រដែលមានតម្លៃស្មើ

- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស បេក្ខជនមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេស ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋានរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសសិស្ស និស្សិតឲ្យចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

**មាត្រា៥.-**

នាយកនៃវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន និងមាននាយករងមួយចំនួន តាមការចាំបាច់។

វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូនក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈឲ្យបានទៀងទាត់តាមការកំណត់។

**មាត្រា៦.-**

វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា កាន់កាប់បញ្ជិកាគណនេយ្យដោយឡែកតាមប្រព័ន្ធគណនេយ្យសាធារណៈ ដែលត្រូវឧបត្ថម្ភដោយថវិកាជាតិនិងប្រភពធនធានហិរញ្ញវត្ថុដទៃទៀតសម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧.-**

វិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា ត្រូវរៀបចំកម្មវិធីសិក្សាលម្អិតតាមមុខជំនាញស្របតាមគោលការណ៍ណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងចាប់ដំណើរការបណ្តុះបណ្តាល។

**មាត្រា៨.-**

សិស្ស និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ ហើយទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានវិញ្ញាបនបត្រឬសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រដែលផ្តល់ឲ្យដោយវិទ្យាស្ថានអភិវឌ្ឍន៍សហគ្រិនភាពកម្ពុជា-ឥណ្ឌា នឹងត្រូវទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញនិងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៩.-**

អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៦១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតមន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើតមន្ទីរសារការីមួយ ដែលមានឈ្មោះថា **មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា (SETHAVITOU Notary Public of the Kingdom of Cambodia)**

សរសេរកាត់ជាភាសាខ្មែរ "**ម.ស.ស**" និងសរសេរកាត់ជាភាសាអង់គ្លេស "**S.H Notary Public**" ។

**មាត្រា ២.-**

មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅអគារលេខ ៧៣ ផ្លូវលេខ ១២៦ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**មាត្រា ៣.-**

មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា មានតួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលធ្វើកិច្ចសន្យា ឬលិខិតគតិយុត្តទាំងឡាយដែលរូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទត្រូវការ
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ កិច្ចការគ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ផ្តល់ការបញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន និងនីតិបុគ្គលគ្រប់ប្រភេទ
- ផ្តល់យថាភូតភាពដល់លិខិតគតិយុត្ត ឬកិច្ចសន្យា ឬឯកសារបកប្រែទាំងឡាយ តាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- ស្នើសុំឱ្យស្ថាប័នអនុវត្តធ្វើការអនុវត្តដោយបង្ខំនូវលិខិតគតិយុត្ត ឬកិច្ចសន្យាដែលទទួលបានយថាភូតភាពពីសារការី
- ទទួលបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យានានាតាមច្បាប់តម្រូវ ឬតាមការស្នើសុំរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលគ្រប់ប្រភេទ
- បញ្ជាក់ជានាហត្ថលេខា និងកាលបរិច្ឆេទនៃលិខិតគតិយុត្ត ឬកិច្ចសន្យានានា
- ធ្វើសំណើចុះបញ្ជី ឬចុះលេខាចារឹកទៅស្ថាប័នមានសមត្ថកិច្ច
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃកិច្ចសន្យា លិខិតឯកតោភាគីផ្សេងៗ មតកសាសន៍ និងលិខិតស្នាមគ្រប់ប្រភេទ
- ចេញច្បាប់ចម្លងនៃលិខិតយថាភូត
- និងទទួលធ្វើកិច្ចការផ្សេងៗទៀត ដែលអនុញ្ញាតដោយច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៤.-**

នៅពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន មន្ទីរសារកោរី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវតម្កល់ប្រាក់ចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល នៅធនាគារជាតិនៃកម្ពុជា សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

ក្នុងករណីដែលច្បាប់តម្រូវឱ្យមានការរំលាយមន្ទីរសារកោរី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា ប្រាក់តម្កល់ខាងលើនេះ ត្រូវបង្វិលជូនស្ថាបនិក និងសហភាគា ដែលមានសិទ្ធិស្របច្បាប់ក្នុងការទទួលយក បន្ទាប់ពីបានកាត់កងទូទាត់បំណុល និងកាតព្វកិច្ចទាំងអស់ ដោយរាប់បញ្ចូលទាំងប្រាក់សោហ៊ុយនានាដែលចាំបាច់សម្រាប់ធាននិរន្តរភាពនៃការការពារផលប្រយោជន៍របស់អតិថិជនខ្លួន អនុលោមតាមបែបបទ និងនីតិវិធីជាធរមាន។

ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា មន្ទីរសារកោរី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចបង្កើតបន្ថែមនូវយន្តការហិរញ្ញប្បទាន ឬយន្តការធានាផ្សេងទៀតដែលខ្លួនយល់ថាសមស្របសម្រាប់បង្កើនទំនុកចិត្តរបស់ពលរដ្ឋ វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះសេវារបស់ខ្លួន។

ទំនាក់ទំនងគតិយុត្តរវាងស្ថាបនិក និងសហភាគា ត្រូវកំណត់ដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដែលត្រូវអនុម័តដោយសារកោរីដែលទទួលបានការតែងតាំងតាមមាត្រា ៥ នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

ត្រូវបានតែងតាំងជាសារកោរី នូវបុគ្គលដែលមានរាយនាមដូចខាងក្រោម ៖

១-លោក **នាក់ សើគីរ៉ន** ដើម្បីបំពេញមុខងារជាប្រធានមន្ទីរសារកោរី សេដ្ឋាវិទូ

២-លោក **ជាវ អានសាន** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារកោរី សេដ្ឋាវិទូ

៣-លោក **ម្ជូន សារៈមុនី** ដើម្បីបំពេញមុខងារជាអនុប្រធានមន្ទីរសារកោរី សេដ្ឋាវិទូ

៤-លោក **ទី ហ្សានិត** ដើម្បីបំពេញមុខងារជាសមាជិកមន្ទីរសារកោរី សេដ្ឋាវិទូ។

ក្នុងករណីចាំបាច់ មន្ទីរសារកោរី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា អាចធ្វើការជ្រើសរើសសារកោរីដែលទទួលបានការតែងតាំងពីរាជរដ្ឋាភិបាល ឬបុគ្គលិកផ្សេងទៀតសម្រាប់ជួយបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន។

**មាត្រា ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ មន្ទីរសារការី សេដ្ឋាវិទូ នៃព្រះរាជាណាចក្រកម្ពុជា និងសាមីខ្លួនដូចចែងក្នុងមាត្រា ៥ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៦២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ។

**មាត្រា២ ..**

អនុក្រឹត្យនេះ មានគោលដៅកំណត់ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងារក្នុងវិស័យសុខាភិបាល ប្រាក់បំណាច់ប៉ះពាល់សុខភាពបន្ថែមលើបៀវត្សប្រចាំខែជូនបុគ្គលិកមន្ត្រីសុខាភិបាលធ្វើការងារកំចាត់ជំងឺរបេង ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ឱ្យទៅជាប្រាក់បំណាច់មុខងារសុខាភិបាល និង ឱ្យមានការរួមបញ្ចូលតែមួយនូវប្រាក់បំណាច់មុខងាររដ្ឋបាលទូទៅ ប្រាក់បំណាច់ប៉ះពាល់សុខភាពបន្ថែមលើបៀវត្សប្រចាំខែជូនបុគ្គលិកមន្ត្រីសុខាភិបាលធ្វើការងារកំចាត់ជំងឺរបេង ប្រាក់ហានិភ័យតំបន់ និងប្រាក់ហានិភ័យសុខភាពបច្ចុប្បន្នរបស់មន្ត្រីរាជការស៊ីវិលនៃក្រសួងសុខាភិបាល ឱ្យទៅជាប្រាក់បំណាច់មុខងាររដ្ឋបាល។

**មាត្រា៣ ..**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលនិងមន្ត្រីកម្មសិក្សានៃក្រសួងសុខាភិបាល។

**មាត្រា៤ ..**

ប្រាក់បំណាច់មុខងារសុខាភិបាល ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលកំពុងបំពេញមុខងារក្នុងក្របខណ្ឌមន្ត្រីសុខាភិបាលបឋម ក្របខណ្ឌមន្ត្រីសុខាភិបាលមធ្យម និងក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់នៃក្រសួងសុខាភិបាល ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ១ | គិលានុបដ្ឋាកបឋម | ១៥០ ០០០ |
| ២ | ឆ្មបបឋម | ១៥០ ០០០ |
| ៣ | អ្នកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម | ១៥០ ០០០ |
| ៤ | គិលានុបដ្ឋាកមធ្យម | ១៨០ ០០០ |
| ៥ | ទន្តគិលានុបដ្ឋាកមធ្យម | ១៨០ ០០០ |
| ៦ | ឆ្មបមធ្យម | ១៨០ ០០០ |
| ៧ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | ១៨០ ០០០ |
| ៨ | អ្នកព្យាបាលដោយចលនាមធ្យម | ១៨០ ០០០ |
| ៩ | អនុប្រធានមណ្ឌលសុខភាព | ១៨៥ ០០០ |
| ១០ | អនុប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ១៨៥ ០០០ |
| ១១ | ប្រធានមណ្ឌលសុខភាព | ១៩០ ០០០ |
| ១២ | អនុប្រធានមន្ទីរពេទ្យបង្អែកស្រុក | ១៩០ ០០០ |
| ១៣ | អនុប្រធានការិយាល័យស្រុកប្រតិបត្តិ | ១៩០ ០០០ |
| ១៤ | អនុប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ១៩០ ០០០ |
| ១៥ | ប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ១៩០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ១៦ | អនុប្រធានការិយាល័យថ្នាក់កណ្តាល | ១៩០ ០០០ |
| ១៧ | ឆ្មប (បរិញ្ញាបត្រ) | ២០០ ០០០ |
| ១៨ | គិលានុបដ្ឋាក(បរិញ្ញាបត្រ) | ២០០ ០០០ |
| ១៩ | គិលានុបដ្ឋាកឯកទេស | ២០០ ០០០ |
| ២០ | ប្រធានមន្ទីរពេទ្យបង្អែកស្រុក | ២០០ ០០០ |
| ២១ | ប្រធានការិយាល័យស្រុកប្រតិបត្តិ | ២០០ ០០០ |
| ២២ | ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ២០០ ០០០ |
| ២៣ | ប្រធានការិយាល័យថ្នាក់កណ្តាល | ២០០ ០០០ |
| ២៤ | អនុប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | ២០០ ០០០ |
| ២៥ | នាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ២០០ ០០០ |
| ២៦ | ទន្តពេទ្យមធ្យម | ២៥០ ០០០ |
| ២៧ | គ្រូពេទ្យមធ្យម | ២៥០ ០០០ |
| ២៨ | ឱសថការីមធ្យម | ២៥០ ០០០ |
| ២៩ | ទន្តបណ្ឌិត | ៣១០ ០០០ |
| ៣០ | ឱសថការី | ៣១០ ០០០ |
| ៣១ | វេជ្ជបណ្ឌិត | ៣២០ ០០០ |
| ៣២ | ទន្តបណ្ឌិតជំនាញ/ទន្តបណ្ឌិតឯកទេស | ៣៨០ ០០០ |
| ៣៣ | វេជ្ជបណ្ឌិត(ជំនាញ/អនុបណ្ឌិត) | ៣៩០ ០០០ |
| ៣៤ | បណ្ឌិតឱសថសាស្ត្រឯកទេស/ឱសថបណ្ឌិត | ៤០០ ០០០ |
| ៣៥ | វេជ្ជបណ្ឌិតឯកទេស | ៤០០ ០០០ |
| ៣៦ | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៦៥០ ០០០ |
| ៣៧ | ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត | ៦៥០ ០០០ |
| ៣៨ | អនុប្រធានឃ្លាំងឱសថកណ្តាល | ៦៥០ ០០០ |
| ៣៩ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៦៥០ ០០០ |
| ៤០ | អនុប្រធានមជ្ឈមណ្ឌលជាតិ | ៦៥០ ០០០ |
| ៤១ | នាយករងមន្ទីរពេទ្យជាតិ | ៦៥០ ០០០ |
| ៤២ | នាយករងវិទ្យាស្ថានជាតិ | ៦៥០ ០០០ |
| ៤៣ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៦៥០ ០០០ |
| ៤៤ | អនុប្រធាននាយកដ្ឋាន | ៦៧០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារសុខាភិបាល (រៀល) |
|---|---|---|
| ៤៥ | ប្រធានមជ្ឈមណ្ឌលជាតិ | ៧៥០ ០០០ |
| ៤៦ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧៥០ ០០០ |
| ៤៧ | នាយកមន្ទីរពេទ្យជាតិ | ៧៥០ ០០០ |
| ៤៨ | ប្រធានឃ្លាំងឱសថកណ្តាល | ៧៥០ ០០០ |
| ៤៩ | នាយកវិទ្យាស្ថានជាតិ | ៧៥០ ០០០ |
| ៥០ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៧៥០ ០០០ |
| ៥១ | សាស្ត្រាចារ្យមហាបរិញ្ញា | ៧៧០ ០០០ |
| ៥២ | ប្រធាននាយកដ្ឋាន | ៧៨០ ០០០ |
| ៥៣ | សកលវិទ្យាធិការរង | ៧៨០ ០០០ |
| ៥៤ | អគ្គាធិការរង | ៧៩០ ០០០ |
| ៥៥ | អគ្គនាយករង | ៧៩០ ០០០ |
| ៥៦ | សកលវិទ្យាធិការ | ៨០០ ០០០ |
| ៥៧ | អគ្គាធិការ | ៨២០ ០០០ |
| ៥៨ | អគ្គនាយក | ៨២០ ០០០ |

**មាត្រា៥ ..**

មន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌមន្ត្រីសុខាភិបាលបឋម ក្របខណ្ឌមន្ត្រីសុខាភិបាលមធ្យម និងក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់នៃក្រសួងសុខាភិបាលកំពុងបម្រើការងារក្នុងក្រសួងសុខាភិបាល ដែលត្រូវបានតែងតាំងឱ្យកាន់មុខតំណែងណាមួយក្នុងរចនាសម្ព័ន្ធនៃក្រសួងសុខាភិបាល ត្រូវទទួលបានប្រាក់បំណាច់មុខងារផ្អែកលើប្រភេទក្របខណ្ឌប្រសិនបើប្រាក់បំណាច់មុខងារនៃមុខតំណែងនោះមានកម្រិតទាបជាង។

**មាត្រា៦ ..**

ប្រាក់បំណាច់មុខងាររដ្ឋបាល ជាប្រាក់បំណាច់មុខងារប្រចាំខែដែលត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលនៃក្របខណ្ឌភ្នាក់ងាររដ្ឋបាល ក្របខណ្ឌលេខាធិការរដ្ឋបាល ក្របខណ្ឌមន្ត្រីក្រមការ ក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលកំពុងបំពេញមុខងារក្នុងមុខតំណែងនៅក្នុងរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងាររដ្ឋបាល(រៀល) |
|---|---|---|
| ១ | ភ្នាក់ងាររដ្ឋបាល | ១០៥ ០០០ |
| ២ | លេខាធិការរដ្ឋបាល | ១០៥ ០០០ |
| ៣ | មន្ត្រីក្រមការ | ១២៦ ០០០ |
| ៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ១៦៤ ០០០ |

**មាត្រា៧ ..**

ប្រាក់បំណាច់មុខងារដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ នេះតទៅ។

**មាត្រា៨ ..**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៩ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៩៦២...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំង លោក **ពេជ្រ ពោធិ** ជាប្រធាននាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ នៃក្រសួងផែនការ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "៣"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៩៦៣.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងសមាសភាពក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៣/១០៦២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការផ្ទេរសាលាភូមិន្ទរដ្ឋបាល ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២១៤/១៩៥ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/០៤៩៥/៤០/ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសាលាភូមិន្ទរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីលក្ខន្តិកៈរបស់សាលាភូមិន្ទរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-**

តែងតាំងសមាសភាពក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ពេជ្រ ប៊ុនធិន** | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២- ឯកឧត្តម | **ច័ន្ទ តានី** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម | **ព្រុំ សុខា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ឯកឧត្តម | **ណាត ប៊ុនរឿន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- ឯកឧត្តម | **ស៊ា កុសល** | អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៧- ឯកឧត្តម | **អ៊ឹម ថុង** | សាស្ត្រាចារ្យឧត្តមសិក្សា | សមាជិក |
| ៨- ឯកឧត្តម | **ខៀវ ថវិកា** | សាស្ត្រាចារ្យឧត្តមសិក្សា | សមាជិក |
| ៩- ឯកឧត្តម | **ស៊ុំ ម៉ាប់** | នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ចំនួន ០៣ រូប របស់ក្រសួង ចំនួន ២ ពីឋានន្តរស័ក្តិអនុមន្ត្រី ទៅឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| | **ក្រសួងផែនការ** | | |
| ១ | លោក **គៀង រស្មី** | ពីអនុមន្ត្រី ថ្នាក់លេខ **១១** | ទៅវរមន្ត្រី ថ្នាក់លេខ **១០** |
| | **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | |
| ២ | លោក **ជា ដារ៉ា** | ពីអនុមន្ត្រី ថ្នាក់លេខ **១០** | ទៅវរមន្ត្រី ថ្នាក់លេខ **១០** |
| ៣ | លោក **សួន សុផល** | ពីអនុមន្ត្រី ថ្នាក់លេខ **១០** | ទៅវរមន្ត្រី ថ្នាក់លេខ **១០** |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា “២”*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៦៥.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តម្លើងឋានន្តរស័ក្តិ និងថ្នាក់តាមអតីតភាពការងារ ជូនមន្ត្រីរាជការចំនួន ២១ រូប ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១៤ តទៅ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោកជំទាវ **រស់ ច័ន្ទផល្លី** | ពីវរមន្ត្រី ថ្នាក់លេខ ៤ | ទៅវរមន្ត្រី ថ្នាក់លេខ ១ |
| ២ | ឯកឧត្តម **អ៊ុំ សំអាង** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |

| | | | |
|---|---|---|---|
| ៣ | ឯកឧត្តម **ញ៉ឹក កោសល្យវិទ្យា** | ពីវរមន្ត្រី ថ្នាក់លេខ ៥ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៤ | ឯកឧត្តម **ជា យុពា** | ពីវរមន្ត្រី ថ្នាក់លេខ ៧ | ទៅវរមន្ត្រី ថ្នាក់លេខ ៣ |
| ៥ | ឯកឧត្តម **តឹករ៉េត សំរេច** | ពីវរមន្ត្រី ថ្នាក់លេខ ៦ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៦ | ឯកឧត្តម **នុត បូពិណ្ណារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៧ | ឯកឧត្តម **ថៅ ជេដ្ឋា** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨ | ឯកឧត្តម **អៀង ទុន្ធា** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩ | ឯកឧត្តម **វង្ស សំអាង** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ១០ | លោក **ញ៉ៀម ម៉ុនធឿន** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ១១ | លោក **វ៉ាន់ ច័ន្ទតារា** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៥ |
| ១២ | អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ខេមាវត្តី** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |
| ១៣ | ឯកឧត្តម **ស្ងួស យ៉ារ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៤ | ឯកឧត្តម **ឃុន សុខា** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៥ | ឯកឧត្តម **ឃុន ហេង** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ១៦ | លោក **ឡេង តុលា** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៧ | ឯកឧត្តម **ទ្រី ត្រាយ** | ពីវរមន្ត្រី ថ្នាក់លេខ ៨ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៨ | ឯកឧត្តម **ស្វាយ សុវណ្ណរិទ្ធិ** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៦ |
| ១៩ | ឯកឧត្តម **គឹម សៃហៀង** | ពីវរមន្ត្រី ថ្នាក់លេខ ១០ | ទៅវរមន្ត្រី ថ្នាក់លេខ ៨ |
| ២០ | ឯកឧត្តម **សុកផេង** | ពីវរមន្ត្រី ថ្នាក់លេខ ៩ | ទៅវរមន្ត្រី ថ្នាក់លេខ ៧ |
| ២១ | លោកជំទាវ **ឆាយ សំនៀង** | ពីអនុមន្ត្រី ថ្នាក់លេខ ១ | ទៅវរមន្ត្រី ថ្នាក់លេខ ៤ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៣៦៦. អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការតម្លើងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទទួលយល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
ខ- ភូមិខ្មែរលើ ភូមិបែកបក ភូមិគោករកា ភូមិព្រៃធំ ភូមិស្វាយចេក ភូមិឆ្លក ភូមិជំរៅ ភូមិជ្រេស ភូមិអណ្តូង ភូមិត្រពាំងសំព័រ ភូមិអង្គតាកូវ និងភូមិទួលសំពៅ
- តម្លៃ ១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ១០ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ៧ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

៣- សង្កាត់សំរោង មាន០៤ភូមិ គឺ ÷ ភូមិគ្រួស ភូមិសំរោងជើង ភូមិសំរោងកណ្តាល និងភូមិសំរោងត្បូង
- តម្លៃ ១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ៧ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ៤ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ
- តម្លៃ ២ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ (ដីបឹង)

៤- សង្កាត់ពញាពន់ មាន ០៨ភូមិ គឺ ÷ ភូមិធំជើង ភូមិធំត្បូង ភូមិត្រពាំងស្នោរ ភូមិត្រពាំងព្រីង ភូមិវែង ភូមិបឹង ភូមិស្រែដូនតូច និងភូមិព្រៃពង្រ ÷
- តម្លៃ ១៥ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ៧ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ៤ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ
- តម្លៃ ២ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ (ដីបឹង)

៥- សង្កាត់ពន្សាំង មាន ២៤ភូមិ គឺ ÷ ភូមិបួនមុខ ភូមិស្វាយឧត្តម ភូមិត្រពាំងអំពិល ភូមិថ្នល់បន្ទាយ ភូមិត្រពាំងទទឹង ភូមិកាន់ទ្រង់ ភូមិត្រពាំងរនាម ភូមិកោះរវៀង ភូមិព្រៃស្វាយ ភូមិតាគល់ ភូមិដើមចាន់ ភូមិបឹងប៉ិច ភូមិឧសភា ភូមិត្នោតខ្ពស់ ភូមិបឹងខ្ទី ភូមិតាស្គរ ភូមិទួលពន្សាំង ភូមិព្រៃស្នួល ភូមិត្រពាំងស្គន់ ភូមិត្រពាំងថ្លាន់ ភូមិចំបក់ធំ ភូមិទួល ភូមិកន្លែងគល់ និងភូមិចុងថ្នល់
- តម្លៃ ៧ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវសង្កាត់
- តម្លៃ ៤ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីជាប់ផ្លូវភូមិ
- តម្លៃ ៣ ដុល្លារ ក្នុងមួយម៉ែត្រក្រឡា ដីពុំជាប់ផ្លូវខាងលើ

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

បណ្ឌិត. អូន ពន្ធមុនីរ័ត្ន

តទៅរាជកិច្ចលេខ ៧៥

១៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១០ សហវ.ឧបក

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០១៤

# សារាចរណែនាំ

## ស្ដីពី

## គោលការណ៍ និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

យោងប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្ដីពីការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួង លេខ ៣៨៤៥ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំស្ដីពីគោលការណ៍ និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម ÷

## ផ្នែកទី ១

## ការគ្រប់គ្រងចំណូល

**១.** អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ត្រូវគ្រោងចំណូល ដែលបានមកពីការផ្ដល់សេវារដ្ឋបាលប្រចាំឆ្នាំ នៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន តាមទម្រង់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលបានកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការគ្រោងគិតចំណូលត្រូវមានមូលដ្ឋាន ឬទិន្នន័យសមស្រប និងការគ្រោងលម្អិតទៅតាមប្រភេទ ឬសេវារដ្ឋបាលនីមួយៗ ដោយផ្អែកតាមតម្លៃសេវា ដែលបានកំណត់ដោយប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃស្ដីពីការផ្ដល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩
Phone : 855-23-724 664 Fax : 855-23-427 798

២. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ ពេលប្រមូល ឬទទួលប្រាក់ចំណូលនៅថ្នាក់រដ្ឋបាលនីមួយៗ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ពដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយចុះចំនួនទឹកប្រាក់នៅលើបង្កាន់ដៃបង់ប្រាក់ស្មើនឹងចំនួនទឹកប្រាក់ជាក់ស្តែងដែលបានទទួលពីអតិថជន។

ការកាត់ទុកចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើការគណនាប្រាក់រង្វាន់សរុប ដោយផ្អែកទៅតាមសមាមាត្រ និងផ្អែកទៅតាមប្រាក់ចំណូលដែលប្រមូលបាន ហើយធ្វើការបែងចែកតាមតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣. ចំណូលពីសេវារដ្ឋបាលរបស់សង្កាត់ចំណុះក្រុង ត្រូវបង់ចូលថវិការបស់សង្កាត់សាមី។ ចំណូលពីសេវារដ្ឋបាលរបស់សង្កាត់ និងខណ្ឌចំណុះរាជធានី ត្រូវបង់ចូលថវិការបស់សង្កាត់ និងខណ្ឌសាមី។

៤. ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តពីចំណូលដែលទទួលបាន និងត្រូវបានចាត់ទុកថា រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលប្រាក់បុរេប្រទាន សម្រាប់ចំណាយផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ក្នុងការផ្តល់សេវារដ្ឋបាល និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព។

ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្តនេះ មិនតម្រូវឱ្យថ្នាក់រដ្ឋបាលនីមួយៗ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធ្វើលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

## ផ្នែកទី ២
## ការគ្រប់គ្រងចំណាយ

១. អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់ ត្រូវគ្រោងចំណាយប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំនៅក្នុងគម្រោងចំណាយថវិកាប្រចាំឆ្នាំរបស់ខ្លួន តាមទម្រង់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការគ្រោងគិតចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើការគណនាផ្អែកតាមលទ្ធផលនៃតួលេខចំណូលសរុប ដែលបានគ្រោងគិតរួច និងផ្អែកតាមអត្រាផ្តល់ប្រាក់រង្វាន់សរុប នៃប្រភេទសេវារដ្ឋបាលនីមួយៗ។

២. ការចំណាយប្រាក់រង្វាន់លើកទឹកចិត្តគឺត្រូវគោរពតាមប្រកាសអន្តរក្រសួងរវាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ចំនួនលើកនៃការបែងចែក និងបើកប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីរាជការ និងរាល់ការចំណាយសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ត្រូវផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតម្រូវការចាំបាច់ និងបន្ទាន់ ដើម្បីលើកកំពស់គុណភាព ប្រសិទ្ធភាព និងជំរុញឱ្យមានតម្លាភាព ក្នុងការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

៣. ការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តគឺ រជ្ជទេយ្យករចំណូលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ជារៀងរាល់ខែត្រូវធ្វើការបូកសរុបចំនួនទឹកប្រាក់បុរេប្រទានដោយគិតត្រឹមថ្ងៃទី ២៥ នៃខែនីមួយៗ និងគិតត្រឹមថ្ងៃទី ៣១ ចំពោះខែ ធ្នូ តាមរយៈការប្រើប្រាស់តារាងស្តីពីការគណនាប្រាក់រង្វាន់ ដែលចំនួនទឹកប្រាក់សរុបនេះ ត្រូវប្រើជាមូលដ្ឋានសម្រាប់ចុះនៅក្នុងសលាកប័ត្របង់ចំណូលថវិកាថ្នាក់ក្រោមជាតិផង និងចុះនៅក្នុងអាណត្តិនិយ័តកម្មផង។ ការទូទាត់ប្រាក់បុរេប្រទាននេះ ជាការអនុវត្តនីតិវិធីដោយឡែក ដែលមិនតម្រូវចាំបាច់ឲ្យភ្ជាប់មកជាមួយនូវសក្ខីប័ត្រចំណាយជាក់ស្តែងពេញលេញឡើយ។

ចំពោះការបើកប្រាក់រង្វាន់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត និងអង្គភាពនានាដែលមានចំណែកនៃប្រាក់រង្វាន់ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ជាអ្នករៀបចំប្រតិបត្តិតាមស្មារតីនៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

រជ្ជទេយ្យករចំណូលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសលាកប័ត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអាណត្តិនិយ័តកម្មដែលបានរៀបចំរួច ដោយភ្ជាប់មកជាមួយនូវតារាងស្តីពីការគណនាប្រាក់រង្វាន់ របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយ) ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្របង់ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងបន្តអនុវត្តនីតិវិធីលើការរៀបចំអាណត្តិនិយ័តកម្ម ហើយចុងក្រោយបញ្ជូនសំណុំឯកសារទាំងនេះព្រមគ្នាក្នុងពេលតែមួយទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យ និងធ្វើការកត់ត្រាជាចំណូលថវិកា និងចំណាយថវិកា ដែលរជ្ជទេយ្យករបានកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត។

រជ្ជទេយ្យករចំណូលនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនសលាកប័ត្របង់ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ (មិនចាំបាច់ភ្ជាប់អាណត្តិនិយ័តកម្ម) ដោយភ្ជាប់ជាមួយតារាងស្តីពីការគណនាប្រាក់រង្វាន់ របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក (ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ជាមួយ) ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្របង់ចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ ហើយចុងក្រោយរជ្ជទេយ្យករចំណូលនៃរដ្ឋបាលឃុំ សង្កាត់ ត្រូវបញ្ជូនឯកសារទាំងនេះ ព្រមជាមួយនឹងអាណត្តិនិយ័តកម្មដែលបានរៀបចំរួចដោយរដ្ឋបាលឃុំ សង្កាត់ ក្នុងពេលតែមួយទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យនិងធ្វើការកត់ត្រាជាចំណូលថវិកា និងចំណាយថវិកា ដែលរជ្ជទេយ្យករបានកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត។

៤. ករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិណាមួយ មិនយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តឲ្យបានទាន់ពេលវេលា ឬមិនបានរៀបចំសំណុំឯកសារដើម្បីធ្វើការទូទាត់ទេនោះ នឹងត្រូវប្រឈមមុខទៅនឹងការពិន័យរដ្ឋបាលពីប្រមុខរាជរដ្ឋាភិបាលជាយថាហេតុ។



W

## ផ្នែកទី ៣
## ការកត់ត្រាតាមដាននិងការទទួលខុសត្រូវ

ការកត់ត្រាតាមដានចំណូលថវិកាដែលប្រមូលបាន និងចំណាយថវិកាសម្រាប់ផ្តល់រង្វាន់លើកទឹកចិត្ត ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងការអនុវត្តនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តត្រូវបាន កំណត់ដូចតទៅ÷

**១.** នៅពេលប្រមូល ឬទទួលបានចំណូលថវិកាពីការផ្តល់សេវារដ្ឋបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រជ្ជទេយ្យករចំណូលត្រូវតាមដានចំណូលថវិកាចែកចេញជាពីរចំណែកៈ

- **ចំណែកទី១:** ជាចំណូលថវិកាដែលត្រូវបង់ចូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ជាសាច់ប្រាក់។ ចំណែកចំណូលថវិកានេះជាចំណូលពិតដែលក្នុងខែនីមួយៗរជ្ជទេយ្យករចំណូល ត្រូវបង់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិការដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែល ជាសក្ខីប័ត្រយោងសម្រាប់កត់ត្រាជាចំណូលថវិការដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។
- **ចំណែកទី២:** ជាចំណូលថវិកាដែលចាត់ទុកថាជាប្រាក់បុរេប្រទានសម្រាប់ចំណាយលើប្រាក់រង្វាន់ លើកទឹកចិត្ត។ រជ្ជទេយ្យករចំណូលត្រូវរក្សាទុកចំណែកចំណូលថវិកានេះសម្រាប់ចំណាយលើប្រាក់រង្វាន់លើក ទឹកចិត្ត ហើយអាចដកចំណាយជាបណ្តើរៗ ផ្អែកទៅតាមតម្រូវការចាំបាច់និងបន្ទាន់នានា ដែលស្ថិតក្រោម ការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។ ជារៀងរាល់ខែ រជ្ជទេយ្យករចំណូលត្រូវបូកសរុបចំណូលថវិកាចំណែកទី២នេះ និងធ្វើសលាកប័ត្របង់ចំណូលថវិកា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីជាមូលដ្ឋានសម្រាប់កត់ត្រាជាចំណូលថវិការដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និងសម្រាប់ការអនុវត្តនីតិវិធីទូទាត់លើការផ្តល់ប្រាក់រង្វាន់លើក ទឹកចិត្ត។

**២.** ក្រោយពេលអនុវត្តនីតិវិធីទូទាត់ថវិកាបុរេប្រទានលើរង្វាន់លើកទឹកចិត្ត សលាកប័ត្របង់ចំណូល ថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់នៃចំណូលចំណែកទី២ខាងលើ និងអាណត្តិ និយ័តកម្មចំណាយថវិកាលើប្រាក់រង្វាន់ ជាសក្ខីប័ត្រយោងសម្រាប់រជ្ជទេយ្យករចំណូល និងគណនេយ្យករមុខការ នៃរតនាគាររាជធានី ខេត្ត ធ្វើគណនេយ្យកម្មដោយកត់ត្រាព្រមគ្នាជាចំណូលនិងចំណាយថវិកាដែលមានទឹក ប្រាក់ស្មើគ្នា។

## ផ្នែកទី ៤
## ការអនុវត្តថវិការង្វាន់លើកទឹកចិត្តឆ្នាំ២០១៤

**១.** រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវកត់ត្រាចំណូលដែលបានមកពីការ ផ្តល់សេវារដ្ឋបាលដូចបានកំណត់នៅក្នុងប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

តាមទម្រង់ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលបានកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យឡើងវិញនូវឥណទានចំណាយសម្រាប់ប្រាក់រង្វាន់ (អនុគណនី៦៤៣៣) ក្នុងករណីមិនបានគ្រោងឥណទាននេះនៅក្នុងសៀវភៅថវិកាប្រចាំឆ្នាំ២០១៤ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យឥណទានចំណាយមិនបានគ្រោងទុក ឬឥណទានចំណាយណាដែលមិនចាំបាច់ ដើម្បីលើកសំណើសុំបង្វែរឥណទាន ផ្អែកតាមសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលពុំមានឥណទានគ្រប់គ្រាន់សម្រាប់ស្នើសុំបង្វែរឥណទាន ត្រូវលើកសំណើសុំបន្ថែមឥណទានសម្រាប់ចំណាយលើប្រាក់រង្វាន់ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយផ្អែកលើការពិនិត្យជាក់ស្តែងនៃចំណែកប្រាក់រង្វាន់ ដែលទទួលបានពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់នីមួយៗ។

រាល់សំណើបង្វែរឥណទាន ឬសំណើសុំបន្ថែមឥណទាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវភ្ជាប់ឯកសារយុត្តិការដែលបញ្ជាក់សក្តានុពលនៃការប្រមូលចំណូលពីការផ្តល់សេវារដ្ឋបាល រួមមានៈ តារាងស្តីពីការគណនាប្រាក់រង្វាន់ របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលពីការផ្តល់សេវារដ្ឋបាល និងគម្រោងស្តីពីការបែងចែកប្រាក់រង្វាន់។

៣. ចំពោះរដ្ឋបាលឃុំ សង្កាត់ ត្រូវរៀបចំសុំកែតម្រូវថវិកាដើម្បីបង្វែរឥណទាន ឬបន្ថែមឥណទានចំណាយសម្រាប់ប្រាក់រង្វាន់ ដោយកត់ត្រាក្នុងអនុគណនី ៦៤៣៣ (រង្វាន់) ជូនក្រុមប្រឹក្សាសាមី ពិនិត្យ ពិភាក្សា និងអនុម័ត រួចបញ្ជូនទៅអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រួតពិនិត្យនីត្យានុកូលភាព និងអនុលោមភាព។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមយ៉ាងមុតមាំ លើស្មារតីទទួលខុសត្រូវខ្ពស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការយកចិត្តទុកដាក់អនុវត្តសារាចរណែនាំនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែងប្រមូលចំណូល ក្នុងដែនសមត្ថកិច្ចរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកៀរគរចំណូលថវិកាបង់ចូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**<u>ចម្លងជូនៈ</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រសួងមហាផ្ទៃ
- អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត............

ក្រុង ស្រុក ខណ្ឌ......

ឃុំ សង្កាត់.............

លេខ:....................

**គោរពជូន**

**លោកប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត.........**

**កម្មវត្ថុ:** សំណើសុំទូទាត់ចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ចំនួន..................៛(ទឹកប្រាក់ជាអក្សរ) ប្រចាំខែ......ឆ្នាំ.......។

**យោង:** -ប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ

-សារាចរណែនាំលេខ.......ចុះថ្ងៃទី........ខែ......ឆ្នាំ...... ស្តីពីគោលការណ៍និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកត្តិយស សូមជម្រាបជូនលោកប្រធានមន្ទីរ ជ្រាបថា សាលាសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ ឃុំ សង្កាត់.......បានប្រើប្រាស់ថវិកា ដែលអនុញ្ញាតជាគោលការណ៍ក្នុងការកាត់ទុកសម្រាប់រង្វាន់លើកទឹកចិត្ត ដែលបានមកពីចំណូលពីការផ្តល់សេវារដ្ឋបាល........ ដែលក្នុងនោះមានចំណែកសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ ឃុំ សង្កាត់....... អង្គភាព.......និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដូចនេះសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ឃុំ សង្កាត់....... ស្នើសុំទូទាត់តាមនីតិវិធីរជ្ជទេយ្យបុរេប្រទានជំពូក ៦៤ ចំនួនទឹកប្រាក់..................៛(ទឹកប្រាក់ជាអក្សរ)។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមន្ទីរ ពិនិត្យនិងសម្រេចតាមការគួរ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

ធ្វើនៅ......., ថ្ងៃទី ......ខែ ..... ឆ្នាំ........

**អភិបាលនៃគណៈអភិបាល/មេឃុំ ចៅសង្កាត់............**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត............

ក្រុង ស្រុក ខណ្ឌ.......

ឃុំ សង្កាត់.............

លេខ:....................

**គោរពជូន**

**លោកប្រធានរតនាគារខេត្ត.........**

**កម្មវត្ថុ:** សំណើសុំកត់ត្រាចំណូល ចំនួន................រ (ទឹកប្រាក់ជាអក្សរ) ចូលថវិការដ្ឋបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ ឃុំ សង្កាត់.......តាមរយៈរជ្ជទេយ្យករចំណូល

**យោង:** -ប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ

-សារាចរណែនាំលេខ......ចុះថ្ងៃទី.......ខែ.......ឆ្នាំ..... ស្តីពីគោលការណ៍និងនីតិវិធីផ្តល់រង្វាន់លើកទឹកចិត្តលើការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូនលោកប្រធានរតនាគារ ជ្រាបថា សាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ ឃុំ សង្កាត់.......សូមស្នើកត់ត្រាចំណូលពីការផ្តល់សេវារដ្ឋបាល........ ដែលជាចំណែកកាត់ទុកសម្រាប់រង្វាន់លើកទឹកចិត្តរបស់សាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ឃុំ សង្កាត់.......អង្គភាព.......និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រចាំខែ.....ឆ្នាំ...... ចូលថវិករដ្ឋបាលរាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ/ ឃុំ សង្កាត់.......។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាន ពិនិត្យនិងសម្រេចតាមការគួរ។

សូមលោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ

ធ្វើនៅ......., ថ្ងៃទី ......ខែ ..... ឆ្នាំ........

**អភិបាលនៃគណៈអភិបាល/មេឃុំ ចៅសង្កាត់............**

**សាលារាជធានី ខេត្ត ........................**
**សាលាក្រុង ស្រុក ខណ្ឌ........................**
**សាលាឃុំ សង្កាត់................................**

**តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្ត ប្រចាំខែ .......... ឆ្នាំ .........**
**លើចំណូលប្រមូលបានពីការផ្តល់សេវាសាធារណៈ និងផាកពិន័យ**
( លម្អិតតាមប្រភេទសេវា និងធ្វើចំណាត់ថ្នាក់ទៅតាមមាតិកាចំណូលថវិកា )

ឯកតា : រៀល

| មាតិកាចំណូលថវិកា | | | | ចំណូលប្រមូលបានក្នុងខែ | ការបែងចែកប្រាក់ចំណូលប្រមូលបាន | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ត្រូវបង់ចូលថវិការដ្ឋបាល....... ( ចំណូលពិត ) | | ការកាត់ទុកសម្រាប់រង្វាន់លើកទឹកចិត្ត | | | | | | | | |
| ជំពូក | គណនី | អនុគណនី | បរិយាយ | | ទឹកប្រាក់ | អត្រា | សរុបទឹកប្រាក់ | ចំណែករដ្ឋបាលសាមី ............ ទឹកប្រាក់ | អត្រា | ចំណែករដ្ឋបាល...... ទឹកប្រាក់ | អត្រា | អង្គភាព......... ទឹកប្រាក់ | អត្រា | មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទឹកប្រាក់ | អត្រា |
| 1 | | | 2 | 3 ( = 4 + 6 ) | 4 = 3 x 5 | 5 | 6 = 7 + 9+11+13 | 7 = 3 x 8 | 8 | 9= 3 x 10 | 10 | 11 = 3 x 11 | 12 | 13 = 3 x 14 | 14 |
| **សរុបចំណូល** | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | |

............, ថ្ងៃទី .... ខែ ..... ឆ្នាំ .......
**អភិបាលខេត្តរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចៅសង្កាត់.........**

ថ្ងៃទី .... ខែ ..... ឆ្នាំ ...
**ប្រធានគណនេយ្យ**

........, ថ្ងៃទី .... ខែ ..... ឆ្នាំ ......
**រដ្ឋនេយ្យករចំណូល**

**សាលារាជធានី ខេត្ត ..........................**
**សាលាក្រុង ស្រុក ខណ្ឌ..........................**
**សាលាឃុំ សង្កាត់..................................**

**ស្តីពីការអនុវត្តចំណូលប្រចាំខែ ............. ឆ្នាំ .........**
**ចំណូលពីការផ្តល់សេវាសាធារណៈ និងផាកពិន័យ**
(លម្អិតតាមមាតិកាចំណូលថវិកា)

ឯកតាគិត : រៀល

| មាតិកាចំណូលថវិកា | | | | ច្បាប់ហិ/វ ២០១៤ | ចំណូលប្រមូលបាន (ថវិកាវដ្ឋបាល........ ) | | | | ការបង់ចំណូលចូលថវិកាវដ្ឋបាល... សម្រាប់រយៈពេល ....... ខែ | | | ចំណូលអនុវត្តនីតិវិធីទូទាត់ សម្រាប់រយៈពេល ...... ខែ | | | បានកត់ត្រា ចំណូលថវិកាវដ្ឋបាល... | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | បរិយាយ | | បណ្តាខែមុន | ក្នុងខែ | បូកយោង | សមាមាត្រ | ត្រូវបង់ | បានបង់ | សមតុល្យ | ត្រូវទូទាត់ | បានទូទាត់ | សមតុល្យ | ទឹកប្រាក់ | សមាមាត្រ |
| 1 | | | | 2 | 3 | 4 | 5 = 3 + 4 | 6 = 5 / 2 | 7 | 8 | 9 = 7 - 8 | 10 | 11 | 12 = 10 - 11 | 13 = 8 + 11 | 14 = 13 / 2 |
| **សរុប** | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |

............ , ថ្ងៃទី .... ខែ ..... ឆ្នាំ .......
**អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចៅសង្កាត់.........**

... , ថ្ងៃទី .... ខែ ..... ឆ្នាំ ...
**ប្រធានគណនេយ្យ**

........ , ថ្ងៃទី .... ខែ ..... ឆ្នាំ .......
**រដ្ឋនេយ្យករចំណូល**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលារាជធានី ខេត្ត**........................
**សាលាក្រុង ស្រុក ខណ្ឌ**........................
**សាលាឃុំ សង្កាត់**................................

**របាយការណ៍ស្តីពីការបែងចែកប្រាក់ខ្វាន់លើកទឹកចិត្តប្រចាំខែ........ឆ្នាំ..........**

**របស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់** ......................................

( គិតចាប់ពីថ្ងៃទី........ ខែ......... ដល់ថ្ងៃទី........ ខែ....... ឆ្នាំ .... )

| លរ. | បរិយាយ | ចំនួនទឹកប្រាក់ | | |
|---|---|---|---|---|
| | | ប្រាក់រៀល | ប្រាក់ដុល្លារ | ទឹកប្រាក់សរុប គិតជារៀល |
| ១ | **សរុបប្រាក់ខ្វាន់ដែលបានកាត់ទុក** | | | |
| ២ | **ប្រាក់ខ្វាន់បើកផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ** | | | |
| ៣ | **ស្ថានភាពចំណាយប្រាក់ខ្វាន់ របស់រដ្ឋបាល**........... | | | |
| ៣.១ | សមតុល្យដើមគ្រា | | | |
| ៣.២ | ប្រាក់វង្វាន់ទទួលបានក្នុងគ្រា | | | |
| ៣.៣ | បានចំណាយក្នុងគ្រា | | | |
| | - ឧបត្ថម្ភមន្ត្រីរាជការ | | | |
| | - ពង្រឹងយន្តការប្រមូលចំណូល | | | |
| ៣.៤ | សមតុល្យចុងគ្រា( ៣.១ + ៣.២ - ៣.៣ ) | | | |

<u>*កំណត់សម្គាល់*</u> : ចំពោះប្រាក់ដុល្លារអាមេរិក ត្រូវបានគិតជាប្រាក់រៀល ផ្អែកលើអត្រាមូលដ្ឋាន ១$ = ៤.០០០រៀល។

............ , ថ្ងៃទី .... ខែ ..... ឆ្នាំ .......
**អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**
**ចៅសង្កាត់**.........

... , ថ្ងៃទី .... ខែ ..... ឆ្នាំ ..
**ប្រធានគណនេយ្យ**

........ , ថ្ងៃទី .... ខែ ..... ឆ្នាំ .......
**រដ្ឋនេយ្យករចំណូល**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត........**

លេខ:....................

**លិខិតពិនិត្យបញ្ជាក់**

**ស្ដីពីចំនួនទឹកប្រាក់ចុះក្នុងសលាកបត្រចំណូលថវិការដ្ឋបាល......**

សម្រាប់នីតិវិធីទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ខែ......ឆ្នាំ.......

**យោង:** -ប្រកាសអន្តរក្រសួងលេខ ៣៨៤៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ប្រកាសអន្តរក្រសួងលេខ ៣៨៥៦ ប្រក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការផ្ដល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ

-សារាចរណែនាំលេខ........ចុះថ្ងៃទី........ខែ.........ឆ្នាំ......... ស្ដីពីគោលការណ៍និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្តលើការផ្ដល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

១. សរុបប្រាក់ចំណូលប្រមូលបាន ......................................រៀល

២. ប្រាក់ចំណូលត្រូវបង់ចូលថវិការដ្ឋបាលសាមី ......................................រៀល

៣. សរុបប្រាក់រង្វាន់លើកទឹកចិត្ត ដែលត្រូវកាត់ទុក ......................................រៀល

ក. ចំណែកប្រាក់រង្វាន់របស់រដ្ឋបាលសាមី ......................................រៀល

ខ. ចំណែកប្រាក់រង្វាន់របស់អង្គភាពពាក់ព័ន្ធ ......................................រៀល

៤. ចំនួនទឹកប្រាក់ដែលត្រូវចុះក្នុងសលាកបត្រចំណូលថវិការដ្ឋបាលសាមី ......................................រៀល

ឯកសារភ្ជាប់:

- សលាបត្រចំណូលថវិការដ្ឋបាលសាមី និងប័ណ្ណបង់ប្រាក់
- តារាងគណនាប្រាក់រង្វាន់លើកទឹកចិត្តពីថ្ងៃទី០១ ខែ.... ដល់ថ្ងៃទី២៥ ខែ.... ឆ្នាំ២០....
- របាយការណ៍ស្ថានភាពអនុវត្តចំណូលប្រចាំខែពីថ្ងៃទី០១ខែ.... ដល់ថ្ងៃទី២៥ ខែ.... ឆ្នាំ២០....
- របាយការណ៍ស្ដីពីការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តពីថ្ងៃទី០១ខែ... ដល់ថ្ងៃទី២៥ ខែ..ឆ្នាំ២០....

ធ្វើនៅ......., ថ្ងៃទី ......ខែ ..... ឆ្នាំ........

**ប្រធាន**

**មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត..........**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១៤៣៤៣.១៤.ឧ.ស.ក.ព្រ.ក.៧

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ១១១/១៤ ក.ត.ស.ព ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន តេហ្វូ តេហ្វូ (ខេមបូឌា) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន តេហ្វូ តេហ្វូ (ខេមបូឌា) (TEFU TEFU (CAMBODIA) CO., LTD.) តំណាងដោយ លោក KITAMI NOBORU សញ្ជាតិជប៉ុន អាយុ៦១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TZ0424546 ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ 315-6, Orihara, Katori-Shi, Chiba-ken, Japan. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កាបូប | ១៥២០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រផលិតកាបូប គេហ្វិ គេហ្វិ (ខេមបូឌា) "*
**ទីតាំងរោងចក្រ៖** *" តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (សង្កាត់កន្ទោក/ភ្លើងឆេះរទេះ/បឹងធំ) ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រ ដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ ៗភាព

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវទិន្នន័យ និងរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយនៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័សអំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខ ការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤
**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋមន្ត្រីស្តីទី**

**សាត សាមី**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១៣៥ [illegible]

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ១០៣៣/១៤ គ.វ.ក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ធី អ័រ ស៊ី អេ ហ្គាម៉ិន ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ធី អ័រ ស៊ី អេ ហ្គាម៉ិន (T.R.C.A GARMENT CO., LTD) តំណាងដោយ លោក CHEN, LIN-CHENG សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 303290953 ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ 10th Floor, No. 426, Lin Shen Bei Street, Zhong San District, Taipei City, Taiwan. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ធី អ័រ ស៊ី អេ ហ្គាម៉ិន "*
**ទីតាំងរោងចក្រ** *" ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋាន ឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពី ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងរាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃយ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ នឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវទិន្នន័យ និងរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាពទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទម្រង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០១៤៧៥ ឧ.ស.ក.ន.ក/ស.ស.ក.ខ.៣

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ១២៦៤/១៤ គ.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហ្វាយ ស្តារ ខតថិន ហ្គាមេន (ខេមបូឌា) លីមីធីត ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វាយ ស្តារ ខតថិន ហ្គាមេន (ខេមបូឌា) លីមីធីត (FIVE STARS COTTON GARMENT (CAMBODIA) LIMITED.) តំណាងដោយ លោកស្រី ZHANG YING សញ្ជាតិចិន អាយុ៤២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G30883604 ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៨ មានអាសយដ្ឋានបច្ចុប្បន្ន៖ Zhejiang Province, China. ធ្វើការបង្កើតសាខារោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ** ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ហ្វាយ ស្តារ ខតថិន ហ្គាមេន (ខេមបូឌា) លីមីធីត សាខាទី១ "*

**ទីតាំងរោងចក្រ៖** *" ភូមិវះពោះ ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិតមុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រអាចគ្រប់គ្រងរោងចក្រ ដោយខ្លួនឯង ឬប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាស របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនត្រូវបានជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។៣

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវទិន្នន័យ និងរបាយការណ៍ ផលិតកម្ម ប្រចាំខែ និងប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បានបង់កម្រៃសេវាវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-ទិន្នន័យ និងរបាយការណ៍ប្រចាំខែ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែនីមួយៗ។

-ទិន្នន័យ និងរបាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណី ខកខានក្នុងការផ្តល់ទិន្នន័យ និងរបាយការណ៍តាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌ ទាំងឡាយនៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗ ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តតាកែវ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ